www.elibraryofcambodia.org
Scanned with CamScanner

ចំណាយរបស់អ្នកនិពន្ធ សំ.សុភារិទ្ធ ២០១៤
សូមជូន
895.9323
សុភ
ស្ស.២
បណ្ណាល័យ ហ៊ុន សែន
HUN SEN LIBRARY
R.U.P.P.
សាកលវិទ្យាល័យភូមិន្ទភ្នំពេញ
0000 405

ប្រលោមលោក

រឿង ស្រែករហែកមេឃ

ចំណាត់ថ្នាក់លេខ៣ពានរង្វាន់អក្សរសិល្ប៍ព្រះរាជសម្ភារ

ដោយ សំ សុភារិទ្ធ

ព.ស ២៥៥៣-គ.ស ២០០៩
សូមរក្សាសិទ្ធិគ្រប់បែបយ៉ាង
www.elibraryofcambodia.org

បណ្ណាគារ អង្គរធំ

ANGKOR THOM BOOK CENTER

Tel: 023 888 886 (4 Lines), Fax: 023 881 577
#261, Kampuchea Krom Blvd (St.128)
Phnom Penh, Cambodia
E-mail: info@atbc.com.kh
Website: www.atbc.com.kh

www.elibraryofcambodia.org

Scanned with CamScanner

ប្រវត្តិរូបសង្ខេប

សំ សុភារិទ្ធ

កើតថ្ងៃព្រហស្បតិ៍ ទី៦ ខែកក្កដា ឆ្នាំ១៩៧៨ នៅភូមិព្រៃភ្លាំ ឃុំជាងទង ស្រុកត្រាំកក់ ខេត្តតាកែវ ដែលជាដីកំណើតនៃប្រទេស អតីតរាជធានី ឬនគរអង្គបុរី ។

-ជាកូនច្បងក្នុងចំណោមបងប្អូន៥នាក់ (ស្រី៤នាក់) ។

-ឪពុកឈ្មោះ សំ ផន ជាសាស្ត្រាចារ្យនៅវិទ្យាល័យអង្គរកា និងម្ដាយឈ្មោះ ឈ្មោះ ... ជាមេផ្ទះ ។

-ពីឆ្នាំ២០០០ដល់ឆ្នាំ២០០៩ និងបន្តទៀត...ធ្វើការងារនៅសារព័ត៌មានកោះសន្តិភាព ក្នុងនាមជាអ្នកកាសែត និងពិនិត្យកែសម្រួលអត្ថបទ ។

-ពីឆ្នាំ១៩៨៣ ដល់ឆ្នាំ១៩៨៩ សិក្សានៅសាលាបឋមសិក្សាអង្គរកា (ស្រុកត្រាំកក់) ។

-ពីឆ្នាំ១៩៨៩ដល់ឆ្នាំ១៩៩២ សិក្សានៅអនុវិទ្យាល័យអង្គរកា ។

-ពីឆ្នាំ១៩៩២ដល់ឆ្នាំ១៩៩៦ សិក្សានៅវិទ្យាល័យ១ឧសភា (ស្រុកត្រាំកក់) ។

-ឆ្នាំ១៩៩៨ សិក្សាវគ្គបណ្ដុះបណ្ដាលអ្នកនិពន្ធនៅសមាគមអ្នកនិពន្ធខ្មែរ ។ នៅឆ្នាំនោះបានក្លាយជាសមាជិកសមាគមអ្នកនិពន្ធខ្មែរ ។

-ឆ្នាំ២០០០ សិក្សាវិជ្ជាជីវៈសារព័ត៌មាននៅវិទ្យាស្ថានសារព័ត៌មានកម្ពុជា (ជាវិទ្យាស្ថានរបស់...ក្រសួងព័ត៌មាន) ។

-ពីឆ្នាំ២០០៥ដល់ឆ្នាំ២០០៩ សិក្សាថ្នាក់បរិញ្ញាបត្រនៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ។

ប្រវត្តិស្នាដៃ

-រឿង... : ប្រលោមលោកនេះទទួលពានរង្វាន់ក្នុងការប្រកួតប្រជែងនិពន្ធរបស់វិទ្យាល័យ១ឧសភា (ស្រុកត្រាំកក់)ឆ្នាំ១៩៩៧ និងបោះពុម្ពផ្សាយនៅឆ្នាំ២០០៨ ។

-ទទួលបានប្រាក់រង្វាន់លេខ១ក្នុងកម្មវិធីប្រកួតនិពន្ធ... នៅឆ្នាំ១៩៩៧ ។

www.elibraryofcambodia.org

Scanned with CamScanner

-រឿងទឹកមន្តមេត្តា : កំណាព្យស្នាដៃផ្នែកកំណាព្យបីរូបក្នុងរាជធានី ជ័យលាភីចំណាត់ថ្នាក់លេខ១ ពានរង្វាន់អក្សរសិល្ប៍ព្រះសីហនុរាជលើកទី២ នៅឆ្នាំ១៩៩៤ ពីសមាគមអ្នកនិពន្ធខ្មែរ ។

-រឿងជីវិតអ្នកប្រយុទ្ធ : រឿងខ្លីជ័យលាភីចំណាត់ថ្នាក់លេខ១ ពីរង្វាន់ទស្សនពិភពលោកអង្គការ ជាតិ-កម្ពុជា នាឆ្នាំ១៩៩៨ ។

-រឿងពេលវេលារបស់យុវវ័យ : ជ័យលាភីចំណាត់ថ្នាក់លេខ៤ ពីរង្វាន់ទស្សនពិភពលោកអង្គការជាតិ-កម្ពុជានាឆ្នាំ១៩៩៨ ។

-រឿងសំណាកអនុស្សាវរីយ៍ : ប្រលោមលោកបោះពុម្ពផ្សាយនៅឆ្នាំ២០០១ (ស្នាដៃបោះពុម្ពផ្សាយលើកដំបូង) ទទួលបានវិញ្ញាបនបត្រសរសើរពីសមាគមអ្នកនិពន្ធខ្មែរនៅបរទេស និងបោះពុម្ពលើកទី២នៅឆ្នាំ ២០០៩ ។

-រឿងពេលថ្ងៃរះ : ប្រលោមលោក (ស្នាដៃផ្នែកប្រលោមលោកដំបូងក្នុងអាជីព) ជ័យលាភីចំណាត់ថ្នាក់លេខ២ពានរង្វាន់អក្សរសិល្ប៍ព្រះ បាទសុរាម្រិត ពីក្រសួងវប្បធម៌និងវិចិត្រសិល្បៈនាឆ្នាំ២០០០ និងបោះពុម្ពផ្សាយនៅឆ្នាំ២០០២ បន្ទាប់មកបោះពុម្ពលើកទី២ នាឆ្នាំ២០១៨ ។ ស្នាដៃនេះក៏បានតម្រូវជាកាតនិមានចាក់ផ្សាយតាមវិទ្យុ នានាផងដែរនៅឆ្នាំ២០០១ ។

-រឿងសែនឆ្ងាញ់ : កំណាព្យជ័យលាភីចំណាត់ថ្នាក់លេខ៤ ពីមហា (អភពានរង្វាន់អក្សរសិល្ប៍ព្រះសីហនុរាជនាឆ្នាំ២០០១ រៀបចំឡើងដោយសមាគមអ្នកនិពន្ធខ្មែរ និងបោះពុម្ពផ្សាយនៅឆ្នាំ២០០៣ ។

-រឿងពេលគ្មានបំរំ : ប្រលោមលោកខ្នាតខ្លី ជ័យលាភីចំណាត់ថ្នាក់លេខ១ នៅឆ្នាំ២០០៣ ពីវិទ្យាស្ថានសិល្បៈនិងវប្បធម៌ខ្មែរនិងបោះពុម្ពផ្សាយក្នុងសៀវភៅកំរងរឿងនិពន្ធថ្មីនាឆ្នាំ២០០៦។

-អត្ថបទ អង្គន្ធ្យូសក្នុងវេលម្ហូបព្រះរាជជនកម្ពុជា : អត្ថបទគរណ៍ព័ត៌មានជ័យលាភីចំណាត់ថ្នាក់លេខ៣នាឆ្នាំ២០០៣ ពីក្លឹបអ្នកកាសែតកម្ពុជាដែលសហការរៀបចំការប្រលងស្នាដៃ អត្ថបទសារព័ត៌មានជាមួយស្ថានទូតអង់គ្លេស ។

-រឿងស្រែកបោកប្រាស : ប្រលោមលោកជ័យលាភីចំណាត់ថ្នាក់លេខ៣ ពានរង្វាន់ព្រះរាជសម្ភារនៅឆ្នាំ២០០៥ ពីក្រសួងវប្បធម៌និង វិចិត្រសិល្បៈបោះពុម្ពផ្សាយនៅឆ្នាំ២០០៩។

-រឿងអាសូរស្នេហ៍ : ប្រលោមលោកបោះពុម្ពផ្សាយនៅឆ្នាំ២០០៣ ។

-កម្រងរឿងប្រលោមលោកខ្លី ចង្រ្កានថ្មី : ប្រលោមលោកបោះពុម្ពផ្សាយនៅឆ្នាំ២០០៧ ។

-វិធីសាស្រ្តតែងអត្ថបទសារព័ត៌មាន : ស្នាដៃបោះពុម្ពផ្សាយនៅឆ្នាំ២០០៨ ។

-រឿងទ្រូងអ្នកក្រ : ប្រលោមលោកបោះពុម្ពផ្សាយនៅឆ្នាំ២០០៩ ។

www.elibraryofcambodia.org

Scanned with CamScanner

ឧទ្ទិសជូន

-ភូមិកំណើត វប្បធម៌ (ស្រុកត្រាំកក់ ខេត្តតាកែវ ជាទីស្រឡាញ់ ។

-លោកម្ដាយ ម៉ៅ ខន អ្នកម្ដាយបង្កើត ដែលបានផ្ដល់កំណើត និងចិញ្ចឹមថែរក្សាបណ្ដុះបណ្ដាល រហូតមក ។

-បងប្អូនញាតិសន្ដានទាំងអស់ ។

-លោកគ្រូ អ្នកគ្រូ ជាអ្នកបង្រៀនខ្ញុំតាំងពីតូចមក (ព្រមទាំងមិត្តភក្ដិទាំងអស់ដែលបានជួយលើកទឹកចិត្តការនិពន្ធរបស់ខ្ញុំ ។

សូមឲ្យលោកទាំងអស់ (ប្រកបដោយសេចក្ដីសុខ និងភាពរុងរឿងរហូត ។

- លោកតាតាំ ឡៀង (ស្លាប់ឆ្នាំ១៩៨៣) ។
- លោកយាយឃឹម ងីប (ស្លាប់ឆ្នាំ១៩៨៦) ។
- លោកតាគាវ ឃន (ស្លាប់ឆ្នាំ១៩៧៩) ។
- លោកយាយ ជួ រោង (ស្លាប់ថ្ងៃទី២ ខែមីនា ឆ្នាំ២០០៨) ។
- ញាតិកាទាំងប្រាំពីរសន្ដាន ។

សូមវិញ្ញាណក្ខន្ធរបស់លោកបានដល់សុគតិភពកុំបីខាន ។

សំ សុខារិទ្ធ

www.elibraryofcambodia.org

Scanned with CamScanner

សូមឧទ្ទិសស្នាដៃនេះចំពោះ

អ្នកស្រាវជ្រាវកំណើតនៃវិចិត្រសិល្បៈ វប្បធម៌ខ្មែរ ដែលមានកំណើតនៅខេត្តតាកែវជាច្រើន ដែល មានឈ្មោះដូចខាងក្រោម (សូមអភ័យទោសអ្នកដែលខ្ញុំពុំបានរៀបរាប់) :

១-សម្ដេចព្រះអគ្គមហាសង្ឃរាជ ហួត តាត (ស្រុកកំណើតនៅស្រុកត្រាំកក់) ជាកំពូលព្រះសង្ឃដ៏ល្បីល្បាញក្នុងការស្វែងរកសន្តិភាពជូនមនុស្សជាតិ ។

២-សម្ដេចព្រះមហាសុមេធាធិបតី នន់ ង៉ែត (ស្រុកកំណើតនៅឃុំពពេល ស្រុកត្រាំកក់) ជាសម្ដេចព្រះសង្ឃនាយក និងជាព្រះចៅអធិការវត្ត បទុមវតីរាជវរារាម ភ្នំពេញ) ។

៣-ព្រះបញ្ញាសោភ័ណ ភៀត ចន្ទ្រា (ស្រុកកំណើតនៅស្រុកត្រាំកក់) ជាទីប្រឹក្សាសម្ដេចព្រះអគ្គមហាសង្ឃរាជាធិបតីទេព វង្ស ជាគណៈថ្នាក់កណ្ដាលយស ជាព្រះមេគណខេត្តព្រះសីហនុ និងជាចៅអធិការវត្តលើកញ្ញាណ ។

៤-លោកគ្រូ ឃី សាន (ស្រុកកំណើតនៅភូមិឯកភាព ឃុំបឹងត្រាញ់ខាងត្បូង ស្រុកសំរោង) ជាគ្រូនិងជាសិល្បករយីកេដ៏ល្បីល្បាញ ។

៥-លោកតាឡុង មាន (ស្រុកកំណើតនៅឃុំជាងទង ស្រុកត្រាំកក់) ជាគ្រូ និងជាសិល្បករយីកេដ៏ល្បីល្បាញ ។

៦-អ្នកស្រីណាករ សំណាង (ស្រុកកំណើតនៅស្រុកបាទី) ជាតួឯកយីកេ ប្រចាំវិទ្យុជាតិ ។

៧-លោកតាកាន់ សុឃី (ស្រុកកំណើតនៅឃុំសំបួរ ស្រុកទ្រាំង) ជាតួឯកយីកេនៃមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តតាកែវ និងជាអ្នកចំរៀងបុរាណ....។

៨-អ្នកស្រីឃុន សារិន (ស្រុកកំណើតនៅឃុំស្រែរនោង ស្រុកទ្រាំង) ជាតួឯកយីកេរបស់មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តតាកែវ និងជាអ្នកចំរៀងបុរាណ...។

៩-អ្នកស្រីឃី ប៊ុំ (ស្រុកកំណើតនៅភូមិឯកភាព ឃុំបឹងត្រាញ់ខាងត្បូង ស្រុកសំរោង) ជាសិល្បករយីកេ និងជាសាស្ត្រាចារ្យបង្ហាត់យីកេនៅសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ ។

១០-លោកយ៉ាន់ ប៊ុរិន (ស្រុកកំណើតនៅស្រុកព្រៃកប្បាស) ជាសិល្បករយីកេ ជាអ្នកនិពន្ធ និងជាសាស្ត្រាចារ្យសិល្បៈបុរាណនៅសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ ។

១១-កញ្ញាឧត្តម ចន្ធារី (ស្រុកកំណើតនៅក្រុងដូនកែវ) ជាតារាចំរៀងបុរាណ-សម័យ និងជាសិល្បករនៃក្រុមសិល្បៈនៃមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តតាកែវ ។

www.elibraryofcambodia.org

Scanned with CamScanner

១៦-កញ្ញាទេព្យ ជិន្នាំកុក (ស្រុកកំណើតនៅក្រុងភ្នំពេញ ជាសាស្ត្រាចារ្យរបាំបុរាណ-ខ្មែរ និងជាសិល្បការិនីពីរោះប្រចាំក្រុមសិល្បៈនៃមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តតាកែវ ។

១៧-លោកកែវ ហ៊ិតយ៉េង (ស្រុកកំណើតនៅខេត្តតាកែវ ជាតួឯករល្ខោនបាសាក់ប្រចាំវិទ្យុជាតិ ។

១៨-អ្នកស្រីប៉ែក សំអុល (ស្រុកកំណើតនៅស្រុកបាទី ជាតួឯករល្ខោនបាសាក់ប្រចាំវិទ្យុជាតិ ។

១៩-លោកការ់ សេង (ស្រុកកំណើតនៅខេត្តតាកែវ ជាសិល្បករល្ខោនបាសាក់ប្រចាំវិទ្យុជាតិ ។

១៦-លោកកែវ សុភ័ណ្ឌ (ស្រុកកំណើតនៅខេត្តតាកែវ អតីតសិល្បករល្ខោនបាសាក់របស់មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តតាកែវ និងផ្លាស់ទៅជាតួឯកល្ខោនបាសាក់របស់មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តកំពង់ចាម ។

១៧-លោកទូច ណាង (ស្រុកកំណើតនៅស្រុកទ្រាំង ជាសិល្បករបុរាណប្រចាំវិទ្យុជាតិ ។

១៨-អ្នកស្រីសោយ ស៊ីផា (ស្រុកកំណើតនៅស្រុកបាទី ជាសិល្បការិនីបុរាណប្រចាំវិទ្យុជាតិ ។

១៩-អ្នកស្រីរ៉ុក សុផា (ស្រុកកំណើតនៅខេត្តតាកែវ ជាអ្នកចំរៀងរាំវង់ និងជាសិល្បការិនីបុរាណប្រចាំវិទ្យុជាតិ ។

២០-អ្នកស្រីកែវ សង្វារពេជ្រ (ប្តូរឈ្មោះអ្នកនាងប៉េង និងវណ្ណា) (ស្រុកកំណើតនៅភូមិពាន្លៃ ឃុំរវៀង ស្រុកទ្រាំង ជាអ្នកចំរៀងរាំវង់ល្បី ។

២១-លោកតាកង្គបញ្ញាំពី (ស្រុកកំណើតនៅស្រុកទ្រាំង ជាអ្នកចំរៀងចាប៉ីដ៏ល្បី ។

២២-ភិក្សុប្រាជ្ញ ពណ៌ (ស្រុកកំណើតនៅស្រុកទ្រាំង ជាអ្នកចំរៀងចាប៉ី ដ៏ល្បី ។

២៣-លោកណុប រិណោម (ស្រុកកំណើតនៅភូមិស្រែខ្វាវ ឃុំរោងទង ស្រុកត្រាំកក់ ជាពពាក្យភាពយន្តដ៏ល្បី ។

២៤-អ្នកនាងព្រំ ផ្កា (ស្រុកកំណើតនៅក្រុងបូនកែវ ជាតារាភាពយន្ត និងជាអ្នកសម្តែងអ្នកប្រយោគទូរទស្សន៍ ។

២៥-លោកហង្ស ផៀងមុនី (ស្រុកកំណើតនៅស្រុកបាទី ជាតារាភាពយន្ត ។

២៦-អ្នកនាងឈិត សុជាតា (ស្រុកកំណើតនៅក្រុងបូនកែវ ជាតារាភាពយន្ត និងជាអ្នកសម្តែងល្ខោនទូរទស្សន៍ ។

www.elibraryofcambodia.org

Scanned with CamScanner

២៧ លោកស៊ិន ស៊ុងវាសី ស្រុកកំណើតនៅស្រុកសំរោង ជាគាយកភាពយន្ត ។

២៨-លោកអាត់ អ៊ីមគួង ស្រុកកំណើតនៅស្រុកទ្រាំង ជាអ្នកសម្ភាសន៍ក្នុងការផ្សាយទូរទស្សន៍ ។

២៩ លោកស៊ិក សង្ខិតសុវណ្ណ ស្រុកកំណើតនៅខេត្តតាកែវ ជាអ្នកទទួលជ័យលាភប្រកួតចម្រៀងជាតិ ។

៣០ អ្នកនាងអ៊ឹង វិមលកញ្ញា ស្រុកកំណើតនៅភូមិពាម្ល ឃុំអង្គាញ់ ស្រុកទ្រាំង ជាតារាចម្រៀងសម័យ ។

៣១-លោករស់ សារ៉ា រសៀលវ៉ន ស្រុកកំណើតនៅឃុំទួលសោភ័យ ស្រុកត្រាំកក់ ជាតារាចម្រៀងសម័យ ។

៣២ អ្នកនាងរស់ សុវិកា ស្រុកកំណើតនៅស្រុកទ្រាំង ជាតារាចម្រៀង ។

៣៣-លោកសុខ សាខន ស្រុកកំណើតនៅខេត្តតាកែវ ជាតារាចម្រៀង ។

៣៤ អ្នកនាងឃុន វណ្ណា ស្រុកកំណើតនៅឃុំត្រើង ស្រុកទ្រាំង ជាតារាចម្រៀង ។

៣៥ កញ្ញា ឃួន អេមរីតា សោភ័ណ ស្រុកកំណើតនៅស្រុកបាទី ខេត្តតាកែវ ជាតារាកំប្លែង ។

៣៦-ឈាវហ្វៃ ស្រុកកំណើតនៅស្រុកបាទី ជាតារាកំប្លែង ។

៣៧ អ្នកនាងការ៉ាយ ស្រុកកំណើតនៅភូមិត្រពាំងទំនប់ក្បួន ស្រុកត្រាំកក់ ធ្លាប់ជាសិល្បករនៃរោងល្ខោនបាសាក់ និងជាតារាកំប្លែង ។

៣៨-លោកទី ឌីវីស ស្រុកកំណើតនៅស្រុកបាទី ជាអ្នកនិពន្ធ ។

៣៩-លោកនូ គន់ ស្រុកកំណើតនៅឃុំអង្គតាសោម ស្រុកត្រាំកក់ ជាអ្នកនិពន្ធ ។

៤០ លោកកាក សារុន ស្រុកកំណើតនៅខេត្តតាកែវ ជាអ្នកនិពន្ធ ។

៤១-លោកឃុន ស៊ឹន ស្រុកកំណើតនៅឃុំរវៀង ស្រុកសំរោង ខេត្តតាកែវ ជាអ្នកនិពន្ធ ។

៤២-លោក សៀក ប៉ុណ្ណ ស្រុកកំណើតនៅភូមិត្នោត ឃុំព្រៃរំដេង ស្រុកគីរីវង់ ជាអ្នកនិពន្ធ ។

៤៣ លោកវង់ ឌិន ស្រុកកំណើតនៅស្រុកត្រាំកក់ ជាអ្នកនិពន្ធ ។

៤៤-លោកវិន វួន ស្រុកកំណើតនៅខេត្តតាកែវ ជាអ្នកនិពន្ធ ។

៤៥ លោក [illegible] និពន្ធ និងជាវិចិត្រករ ។

www.elibraryofcambodia.org

២៦-លោកស្វាយ ម៉េង ស្រុកកំណើតនៅស្រុកកោះក្រូច (ស្រុកក្រាំងកក់ ហើយកំរិតការ ។

២៧ លោក ព្រាក់ បិន ស្រុកកំណើតនៅខេត្តតាកែវ ជាប្រធានបន្ទីរឃ្លាំង និងហិរញ្ញវត្ថុខេត្តតាកែវ និងជាអ្នកនិពន្ធ ។

២៨-អ្នកនាង ឥម សុវណ្ណារី ស្រុកកំណើតនៅខេត្តតាកែវ ជាគ្រូបង្រៀនភាសាជាតិ ។

www.elibraryofcambodia.org

Scanned with CamScanner

សំដីអ្នកនិពន្ធ

-មេឃអប្រិយ! មេឃកំណាច! អោយឬស្សា! មេឃឃោរឃៅ! មេឃអយុត្តិធម៌...ម្ដេច ក៏អ្នកមិនបង្អុរភ្លៀងចុះមក! ម្ដេចក៏អ្នកបំបែកប្ដីខ្ញុំទៅឆ្ងាយ ! អ្នកសប្បាយណាស់ទៅឬពេលឃើញកសិករជួបគ្រោះទុរ្ភិក្ស! អ្នកសប្បាយណាស់ទៅឬពេលឃើញទឹកភ្នែកខ្ញុំ! ឬក៏អ្នកបង្ហូរទឹកភ្នែកនារីកំសត់ម្នាក់នេះជំនួសទឹកភ្លៀង តើអាចទៅរួចដែរឬ? ខ្ញុំស្អប់អ្នកណាស់ ប្រគល់ប្ដីមកអោយខ្ញុំវិញមក!....” ។

នារីទុក្ខសោកស្រែកទៅមេឃបែបនេះ ។ តើហេតុអ្វីមេឃបំបែកប្ដីចេញពីរូបនាង? តើទីបំផុតមេឃប្រគល់ប្ដីមកអោយនាងវិញតាមការទាមទាររបស់នាងទេ?

ភ្នំពេញរាត្រីទី៩ ខែកញ្ញា ឆ្នាំ២០០៥

សំ សុភារិន្ទ

www.elibraryofcambodia.org

Scanned with CamScanner

១-ផ្លូវបំបែក

ក្រោយដែលអាពាហ៍ពិពាហ៍បែកបាក់ទៅនាង ហើយគ្រប់ទិវារាត្រី នាងតែងតែអោបថែថើបក្រេបរសស្នេហ៍កាលនៅសុខ ផ្កាដែលរំលៃក្រអូប លក់ស្កប់ស្កល់លើសពីនារាត្រីកាលដែលទាក់ទងក្លិនផ្កានោះ ពេលនោះក្រោ កាយដៃដែលនាងប្រឹងអោបរឹតតឹងរស់កំហែងរឹង ផ្កាទាំងប៉ុន្មានទៅជា ក្រពើរមិលគុណទាំងទឹកភ្នែក ។ ចាប់ពីពេលដ៏ខ្លាំងនៃទេពព្រាត់ មកពីទុក្ខព្រួយ ការអាល័យអាឡោះ កង្វល់កង្វាក...ដែលចេះតែរលួយរលាយ របស់បុរសតែម្នាក់គត់នៃជីវិតរបស់នាងនាពេលកន្លងទៅ ។

សោកនាដកម្មនេះតែរីងឯងឡើងនៅកណ្តាលវាលរហោស្ថាន ដែលស្ងួតក្រៀម ក្រោះ ។ ទឹកភ្នែកខ្លោចផ្សារបស់ស្ត្រីជាភរិយាកំព្រាប្ដីប្រឹងពីរោះទៅដោយ រាប់ពាន់ដំណក់ទឹកភ្លៀង ដែលរីងស្ងួតពីលើឋានទេវលោកមកលើ ផែនដី ។ អ្នកភូមិទ្រាំដួល ឃុំក្រពាំងទឹកឯងក្បាល ... គ្មានទឹកធ្វើស្រែមួយឆ្នាំកន្លងមកហើយ ឥឡូវពានដែលនេះ... តទៅទៀត ។

www.elibraryofcambodia.org

Scanned with CamScanner

១-ផ្លូវបំបែក

រូបកាយដែលអាពាហ៍ពិពាហ៍ប្រគល់អោយនាង ហើយក្រប់មិនត្រើ នាងតែងតែអោយថែថើបក្រេបរសក្ដេបពីដៃនសុខ ផ្កាដែលផ្លែក្រអូប លក់ស្អុបស្អក់លើសអារនោភត្រីកាលដែលជាក់សរវក្លិនផ្កានោះ នោះនេះក្រោយ កាយដដែលនាងប្រឹងអោយរីកតឹងរសក់កំលោះនៃ ផ្កាដែលកាលម្ដាស់ឲ្យការ ក្រពើរមិលគុណទាំងទឹកភ្នែក ។ ជាការពេលបន្តិចនៃភ្លក់វិញរងគ្រោះ អកពីទុក្ខព្រួយ ការអាលីបេងអាឡោះ កង្វល់កង្វាក...រវាងការស្នេហា របស់បុរសតែម្នាក់គត់នៃជីវិតរបស់នាងនាពេលបន្តិចទៀត ។

សោកនាដកម្មនេះតែរំលងទៀតនៅកណ្ដាលវេហាស្ថាន រីឯមេឃប្រែប្រ ក្រោះ ។ ទឹកភ្នែកខ្លោចផ្សាររបស់ស្ត្រីជាភរិយាស្មោះត្រង់ប្រឹងពីរលាក់វិលលាប ភាប់បានជំនួសទឹកភ្លៀង ដែលរីងស្ងួតពីរបារអោយអាកាសធាតុក្ដៅក្រហាយ ផែនដី ។ អ្នកភូមិស្រែចំការ ឃុំក្រពាំងទំហាងត្បូង (គិតជាព្រៃ ខេត្តតាកែវ គ្មានទឹកធ្វើស្រែមួយឆ្នាំកន្លងមកហើយ ឥឡូវកាលដែលនេះនៅពុំទាន់ការ តទៅទៀត ។

www.elibraryofcambodia.org

Scanned with CamScanner

វស្សាគ្មានផ្កាភក់ សំណាបក្នុងថ្នាលស្ងួតក្រៀមក្រោះរអាក្រក់ក្រៀមរត់ ទាំងស្រពោន ឯសន្ទូងប្រឹងត្រដររស់ទាំងលំបាក ។ អ្នកភូមិដែលរំពឹងតែលើការធ្វើស្រែមួយមុខនេះ ម្នាក់ៗទឹកមុខស្រពោនមិនខុសពីសំណាប និងសន្ទូងរបស់ពួកគាត់ឡើយ ។ មានគ្រួសារខ្លះកំពុងតែពរភនទៅរកការងារស៊ីឈ្នួលអារការទៀតផង ព្រោះឆ្នាំកន្លងមកធ្វើស្រែបានតែពាក់កណ្តាលប៉ុណ្ណោះ ។ នេះហើយជាករុណាកម្មផ្តល់អោយដោយមេឃកំណាច ។

-អូនដួងចិត្តជីវិតបងអើយ! សូមអូនធ្វើអោយស្ងប់រលកទុក្ខព្រួយ វិយោគនេះទៅ ដើម្បីនាំបងអាចចេញដំណើរទៅរាជធានីបានដោយស្ងប់ចិត្ត ស្វះស្វែងរកការងារធ្វើយកប្រាក់កំរៃមកចិញ្ចឹមអូន កូនយើងទាំងពីរ ព្រមទាំងឪពុកយើងផងណាអូន! អូនអើយ! ក្តីសង្ឃឹមរបស់គ្រួសារយើង កសិករឯទៀតត្រូវបានធ្វើអោយស្លោក

ស្រពោន ទៅជាមួយដើមស្រូវអស់ហើយ តើអោយបងទ្រាំនៅទីនេះដើម្បីអ្វី? មច្ឆាក្នុងខែស្រែពេលរដូវរាំងហើយទឹកគោក ខះរីងគង់ប្រឹងនេះ ននៀល ស្វះស្វែងរកស្រះត្រពាំង ។ ជនពិការភ្នែក គង់ពឹងផ្អែកលើដៃទាំងពីរស្ទាបដើម្បីដឹងពីវត្ថុអ្វីមួយ ។ បុប្ផាស្លោកស្រពោន ដោយកំដៅព្រះអាទិត្យគង់ពឹងផ្អែកលើតំណក់សន្សើមរាត្រីកាល។ ចំណែកយើងជាកសិករបើខ្វះទឹកធ្វើស្រែយើងបានអ្វីហូប យើងគួរសំងំស្ងៀមអោយពោះដាច់ ក្រពះស្លាក់ ឬយើងត្រូវស្វះស្វែងរកការងារថ្មី? អូន! តោងការយល់ពីកាតព្វកិច្ចរបស់បងនេះផងចុះកុំឃាត់បងអីណា ។ បុរសពោលពាក្យលួងលោមទាំងអង្វរ

www.elibraryofcambodia.org

Scanned with CamScanner

ខ្លួនប្រពន្ធ ។

នារីបើកទំនួញប្រឈមទុយការឈ្លោះពេកទាំងត្រឹមហើយនោះ ស្រីង ពោលបញ្ចប់ត្រឹមម៉ាត់ទាំងយំ : «ប្រុសស្ងប់ចិត្តទៅ អូនយល់ពីទំនួលខុសត្រូវរបស់បងចំពោះគ្រួសារ ប៉ុន្តែបងគួរគិតដល់ពាក្យចាស់ពោលថា ផ្ញើជិតជាជាងផ្ញើញាតិឆ្ងាយ ។ តើនៅទីក្រុងមានអ្វីប្រសើរទៅ? នៅទីនោះយើងគ្មានបងប្អូនគ្រាន់ពឹងពាក់ គ្មានគោលដៅច្បាស់លាស់ លើសពីនេះ បងគ្មានជំនាញអ្វីពិសេសជាងការធ្វើស្រែផង តើបងអាចរកការងារអ្វីធ្វើ ទទួលបានប្រាក់ផ្ញើមកផ្ទះទៅ? អូនមិនចង់ឃើញជីវិតផ្សងព្រេងរបស់ បងដូចជនកម្មករសំណង់ក្រោមពន្លឺព្រះអាទិត្យទៀតទេ...។ ពេលនេះមេឃដាក់ទោសពួកយើង ប៉ុន្តែយើងក៏នៅសល់ពេលប្រមាណមួយខែទៀតដែរ... គួររង់នៅផ្ទះពុះពារជាមួយការងារកសិកម្មរបស់យើងតទៅទៀត លុះត្រាអស់លទ្ធភាព! អូនជឿជាក់ថាយ៉ាងហោចណាស់ក៏ យើងអាចធ្វើស្រែបាន ពាក់កណ្ដាលដែរ ។ ជាមួយស្ថានភាពបែបនេះយើងខិតខំជំនះជីវភាពរួមគ្នា វានឹងជួយសំរាលការខ្វះខាតរបស់យើងបានមួយថ្នាក់»។

នាងទាក់សំដីកន្លិចទើបពោលបន្ត : «ប្ដីថ្លៃបំផុតជីវិត ម្ចាស់ស្នេហ៍របស់អូន! ម៉្យាងទៀតបងគង់ច្បាស់ហើយ សំបុកណាក៏មានតំលៃ មានសុភមង្គល ពេលមេបាកើតច្រាត់និរាសទៅឆ្ងាយ សល់តែភាពស្ងាត់ជ្រងំបាត់សំលេង ច្រៀងខ្សែខ្មែរ មេឃណាមានភាពរុងរឿងថ្កុំថ្កើងពេលដួងតារានិងដួងព្រះ ខែលិចបាត់ ។ គ្រួសារយើងធ្លាប់រស់នៅជួបជុំគ្នាសុខសាន្ត ទោះជាជួប

www.elibraryofcambodia.org

Scanned with CamScanner

ការប្រឈមនឹងអ្វីៗក៏ដោយ ពុះពារការចាកចេញទៅធ្វើការនឹងខ្វះភាពកក់ក្ដៅ ដែលពុះពារ ត្រីណាចង់ឃ្លាតពីបឹង ប្រពន្ធណាចង់ឃ្លាតពីប្ដី កូនណាចង់ឃ្លាតពីឪពុក... ។ បងគិតទៅមើល តើអូន និងកូនយើងទាំងពីរនឹករលឹកបងរាល់ពេលគ្មានបងនៅក្បែរ? ពីរឹតតែបងនៅត្រមង់ត្រមោចឆ្ងាយស្រុក ពេលឈឺជាប្រនេនណាមើលថែ? ហើយនឹងជួបការលំបាកយ៉ាងណា បើរកការងារមិនបានធ្វើ? ថ្លៃថ្នូរអូនអើយ! ផ្លាស់ចិត្តវិញទៅបង ទីក្រុងមិនមែនជាលំនៅឋានសម្រាប់អ្នកផ្សងព្រេងទៀតឡើយ! ម្ចាស់ភូមិគ្រឹះនៅទីក្រុងខ្ពង់ខ្ពស់ប៉ុណ្ណោះ បងជាម្ចាស់ស្រែខ្ពង់ខ្ពស់ជាងនោះទៅទៀត! កុំទៅណាចោលអូនណាបង អូនសូមអង្វរ...”។

ថ្ងៃរះទាបនៅទិសខាងកើត ។ ការសំរេចចិត្តរបស់ប្ដីដូចជាទឹកប្រាក់មិនរលាយ បុរសត្រឡប់ពាក្យតបទៅប្រពន្ធវិញ ៖ “ភរិយាឧត្តុង្គឧត្ដមនៃបង! សូមអោយចិត្តកុំប្រួលប្រួលពីដំណើរចាកចេញរបស់បងអី នៅឯឆ្ងាយបងនឹងធ្វើខ្លួនជាកុលបុត្រម្នាក់មិនក្រាញនឹងការដេកហាលភ្លៀងខ្យល់ ហើយក្រោកតស៊ូប្រយុទ្ធដោយក្លាហានមិនខ្លាចជីវិតបង់ ។ បងនឹងជំនះរាល់ការលំបាកទាំងឡាយ ដាក់ចិត្តដាក់កាយធ្វើគ្រប់កិច្ចការដែលអាចធ្វើបានអោយតែបានប្រាក់កំរៃផ្ញើមកផ្គត់ផ្គង់ក្រុមគ្រួសាររបស់យើង ។ ជរាភាពអាចសម្លាប់បងបាន ប៉ុន្តែភាពអត់ឃ្លានមិនអាចសម្លាប់បង និងគ្រួសារយើងបានទេ បងត្រូវតែតស៊ូពុះពារ...។ អូនអើយ ទុកអោយបងបំពេញកាតព្វកិច្ចនេះបានចប់ចុងចប់ដើមផងចុះ! ជំនួសការឃាត់ឃាំងសូមជូនពរបងអោយ

www.elibraryofcambodia.org

Scanned with CamScanner

ទៅទីក្រុងរកការងារបានធ្វើដូចបំណងណាស់កូន ។ ដើម្បីរំងាប់ការសោកសោកស្តាយអាណិត កុំអោយត្រូវគិតថានេះគ្រាន់តែជាការឃ្លាតឆ្ងាយមួយគ្រាដូចបក្សា និងត្រីនៅទីរណ្តុក ។ កូនសំណព្វ! ពេលស្ទួចបែកពីព្រលឹមថ្ងៃមួយស្អែក: មកសិនណា៎ ហើយពរកូនតែមួយគត់គឺដើម្បីភាពសុខសាន្តនៃគ្រួសារយើង ។

ខណៈនោះព្រឹទ្ធាចារ្យក្រោកដោយទឹកមុខស្ងួតស្ងប់ ដើរចេញពីក្នុងផ្ទះ តម្រង់សំដៅប្ដីប្រពន្ធទាំងពីររូបដែលឈរនៅមុខផ្ទះ ។ នៅជិតអ្នកទាំងពីរ ព្រឹទ្ធាចារ្យមានប្រសាសន៍ម្ដងៗ : "កូនសំណព្វឪពុកអើយ! អ្នកស្រុកភូមិនានា រមែងមិនបោះបង់ព្រៃភ្នំក្រឹស្ដីស្ងប់ស្ងាត់ឡើយ យ៉ាងណាមិញកសិករមិនអាចបោះបង់ស្រែចំការជាអាយុជីវិតរបស់ពួកគេបានទេ ទោះជាពេលខ្លះធ្វើមិនសូវបានផលដោយសារគ្រោះចង្រៃផ្សេងៗក្ដី ។ តើមកពីលោកមេឃគ្មានយុត្តិធម៌នេះឬ ជាដើមហេតុនាំអោយកូនទៅផ្សងព្រេងរកការងារថ្មីៗ កូនពៅសឪពុកអើយ! ស្ទើររស់មួយជីវិតឪពុកហើយ ឪពុកមិនដែលមានទីពឹងពីអ្វីក្រៅពីធ្វើស្រែឡើយ ។ ដូចជាឪពុកដែរ ឪពុកចង់អោយកូននៅធ្វើស្រែតទៅទៀត ព្រោះពេលវេលានៅសល់ប្រមាណមួយខែទៀតនេះ ឪពុកសង្ឃឹមថាមេឃនឹងបង្អុរភ្លៀងចុះមកមិនខាន ។ ម្យ៉ាងឥឡូវនេះយើងខំព្យាយាមស្ទូងលើដីស្ងួតដោយប្រើពិធីប្រាណជំនួយ នៅពេលមានភ្លៀងធ្លាក់នាពេលខាងមុខយើងនឹងមានសង្ឃឹមណាកូន! ដូចព្រះសង្ឃបិណ្ឌបាតបាយសម្លពីពុទ្ធសាសនិកជន ឪពុកសំណូមពរកូនអោយលះបង់គំនិតចង់ទៅ

www.elibraryofcambodia.org

Scanned with CamScanner

ក្មេងរកការងារនៅក្រុងឆ្ងាយចេញទៅ ជាមួយឪពុក ប្រពន្ធរបស់កូន ឃើញប្រឹងតស៊ូធ្វើស្រែបន្តទៀតណាកូន ។ ឆ្នាំណាចាំរៀងប្រជាប្រិយ របស់កសិករខ្មែរយើងគឺ "ភ្លៀង ភាំងស្ងួត និងជំនន់" វាចៀសមិនផុតទេ។ ស្លាប់ឪពុកនៅក្បៀងកំរៀវនេះរហូតដល់ទីបញ្ចប់ ។

បុរសលោះដងដៃពីរូបកាយនារីយកចិត្តថ្លើមជាងគេ ដាក់ទៅក្រាប សំពះដល់បាតជើងលោកមានគុណអនេកអនន្តទាំងក្តីគោរព : "លោកឪពុកម្ចាស់ជីវិតនៃកូន! សូមលោកឪពុកមេត្តាសន្តោសដល់កូនផង ដែលកូនមិនអាចយល់ស្របតាមសំណូមពរលោកឪពុកបាន! លោកឪពុកធ្លាប់ពាក្យចាស់ពោលថា "ធ្វើស្រែខុសមួយឆ្នាំត្រូវមួយឆ្នាំ" ប៉ុន្តែដីស្រែស្ងួតរីកពីរឆ្នាំជាប់គ្នាមកហើយ ។ កូនមិនអាចស៊ូទ្រាំនឹងការដាក់ទារុណកម្មរស់មហាវេទនាបែបនេះបានទេ ។ កូនមិនចង់ឃើញក្រុមគ្រួសារយើងដាច់ពោះស្លាប់នោះទេ ។ មុនពេលរាត្រីយាងឃាតមកដល់សត្វទាំងឡាយរួតរះចូលទ្រនំ អ្នកគ្រោះដាច់ស្បៀងមកដល់កូនត្រូវតែរួតរះទៅរកការងារធ្វើ" ។

គេងើបឈរអោនឪពុកពោលបន្ត : "ម្ចាស់គុណធំធេងរបស់កូន! កូនមានតែការសូមទោស សូមការអនុញ្ញាតពីលោកឪពុក កូននឹងសូមលានាគ្រាបន្តិចទៀតនេះហើយ ។ លោកឪពុកសូមជួយមើលថែកូនៗរបស់កូនជំនួសកូនផង..." ។

បុរសងាកទៅចាប់ដៃទាំងពីររបស់ប្រពន្ធច្របាច់ថ្នមៗ សំលឹងកែវភ្នែក

www.elibraryofcambodia.org

Scanned with CamScanner

នាងបញ្ជាក់ស្វាមីទាំងទឹកភ្នែកដោយការពេកពន់ប្រមាណ : «អូនបណ្ដូលស្នេហ៍ នៅឈ្មោះបន្តិចទៀតនឹងព្រាត់ប្រាស់បងឃ្លាតពីពិភពលោកអាក្រក់ លើកលែងតែ កាំងកាង ធ្វើអោយបងកាន់តែលំបាកចិត្តខ្លាំងឡើង សូមស្ដាប់អូនហើយ... សូមអូននៅផ្ទះថែរក្សាខ្លួន ថែរក្សាកូនយើង និងលោកឪពុកផងណា៎ ស្ងប់ នៅអោយបានសុខ កុំបារម្ភពីបងអី...!» ។ គេងាកទៅលាលោកគ្រូអាចារ្យ វិញម្តង : «លោកឪពុក! កូនសូមលាហើយ...»។

ប្រពន្ធ និងលោកគ្រូអាចារ្យ បានជូនពរគេជាចុងក្រោយ ។

ជាមួយសាក់កាដូនៅខ្លួនបុរសឈ្មោះជីហានក៏ចេញទៅ ។

លោកគ្រូអាចារ្យសំលឹងកូនពីក្រោយទាំងគ្រវីក្បាលតិចៗ រួចគាត់ដើរ ទៅចាប់ទាញចបកាប់នៅក្បែរនោះកាន់ដើរទៅក្រោយផ្ទះបាត់ ។

ប្រពន្ធនៅតាមសំលឹងប្តីត្រឡប់ត្រដោកខ្លោចផ្សា ក្តុកក្តួលកាន់តែខ្លាំង ឡើង ។ នាងនៅតាមមើលប្តីទាល់តែបាំងបាត់ស្រមោលដោយដើមរុក្ខជាតិ នានា ។

នារីទុក្ខព្រួយខ្ទប់មុខយំតែម្នាក់ឯងយ៉ាងលំបាក ។ គ្មាននរណាអាណិត នាងទេ គ្មាននរណាលួងលោមនាងទេ...ព្រោះមនុស្សតែម្នាក់គត់ដែលធ្លាប់ តែនៅចាំលួងលោមនាងជាអ្នកធ្វើអោយនាងយំ ហើយចាកចេញទៅឆ្ងាយ ពោលនាងទៀត ។ មេឃព្រាត់និរាសពីដួងខែ ត្នោតព្រាត់និរាសពីទឹកដែល ហូរទៅឆ្ងាយ ប្រពន្ធព្រាត់និរាសពីប្ដី...តើភាពខ្លោចផ្សានេះត្រូវការជាងគេភាព នាដកម្មនៃរឿងល្ខោនណាស់ទៅប្ដូរ ទុក្ខខ្លោចផ្សាដែលគ្មានការលួងលោម

www.elibraryofcambodia.org

Scanned with CamScanner

វារឹតតែខ្លោចផ្សាទ្វេដងថែមទៀត ។

នាងប្រឹងងើយសំពឹងទៅវេហាស៍ទាំងផ្ទៃមុខមាំបញ្ចេញកំហឹង ។មេឃមានភាពស្រលះស្រឡះគ្រាព្រឹកព្រលឹម ប៉ុន្តែសោភ័ណភាពនេះវាលុះរបាត់ពណ៌អស់ទៅហើយ ក៏ព្រោះតែកែវភ្នែកងងឹតដោយកំអែលទឹកភ្នែករបស់នារីព្រាត់ប្តី ។ មេឃដដែលដដែលពីមុននាងធ្លាប់គយគន់សំលឹងដោយរស្មីកែវភ្នែកភ្លឺថ្លាក្នុងមនោសញ្ចេតនារីករាយ ជាមួយសោភ័ណភាពគួរជាទីស្រលាញ់ពេញចិត្តនេះ វាប្រែក្លាយជាសត្រូវទៅហើយ ។

ជាមួយកំហឹងនាងក្តាប់ទាត់ ហើយស្រែកខ្លាំងៗតំហាកទៅមេឃ : មេឃអប្រិយ៍ មេឃកំណាច! មេឃឫស្សា! មេឃឃោរឃៅ! មេឃអយុត្តិធម៌!...ម្តេចក៏អ្នកមិនបង្អុរភ្លៀងចុះមក! ម្តេចក៏អ្នកបំបែកប្តីខ្ញុំទៅឆ្ងាយ! អ្នកសប្បាយណាស់ទៅឬពេលឃើញកសិករជួបគ្រោះទុរ្ភិក្ស! អ្នកសប្បាយណាស់ទៅឬពេលឃើញទឹកភ្នែកខ្ញុំ! ឬក៏អ្នកបង្ហូរទឹកភ្នែកនារីកំសត់ម្នាក់នេះជំនួសទឹកភ្លៀង តើអាចទៅរួចដែរឬ? ខ្ញុំសូមអង្វរអ្នកណាស់ ប្រគល់ប្តីមកអោយខ្ញុំវិញមក!...។

* *

*

ចាប់ផ្តើមតែងរឿងនេះនៅរាត្រី៨ ខែកញ្ញា

ចប់នៅវេលាម៉ោង១០រាត្រីទី១៦ ខែកញ្ញា ២០០៥

www.elibraryofcambodia.org

Scanned with CamScanner

២-តំណាក់ភ្ញៀសកណ្តាលទីក្រុង

ទីក្រុងភ្នំពេញ ។ បុរសមកដល់ទីក្រុងប្រៀបបីដូចជនរងគ្រោះលិចសំពៅកណ្តាលមហាសាគរ គេមិនដឹងត្រូវទៅស្នាក់នៅទីណា ទៅទំនាក់ទំនងរកការងារធ្វើនៅកន្លែងណានោះទេ... ។ សំរាប់អ្នកធ្លាប់រស់នៅយូរឆ្នាំគេប្រៀបធៀបទីក្រុងនេះប៉ុនបាតដៃរបស់គេ ផ្ទុយទៅវិញសំរាប់បុរសរសាត់អណ្តែតភ្នំពេញធំសែនធំ ។ ពេលនេះគេដឹងច្បាស់ភ្នំពេញមិនមែនងាយស្រួលដូចការគិតទុកពីមុនមកនោះទេ ។ ក្រៅពីអ្នករត់ម៉ោចក្រយានយន្តពហុល អ្នកធាក់ត្រីចក្រយាន ដែលអេករាក់ទាក់គេដើម្បីបោះជិះយានរបស់ខ្លួន គ្មាននរណាមកស្វាគមន៍គេឡើយ ។

បុរសនេះសំរេចជិះត្រីចក្រយានរបស់ទុរគតជនវ័យកំណាស់ម្នាក់ ក្នុងសំលៀកបំពាក់ចាស់ទ្រុឌទ្រោមពណ៌ពព្លក់ ។ គេជិះទាំងមិនដឹងគោលដៅ ។ កង់ត្រីចក្រយានវិលមិនទាន់បានមួយជុំផង បុរសចំណាស់សួរ : «អ្នកទេសចរដ៏ឧត្តុង្គឧត្តម លោកម្ចាស់អោយខ្ញុំបាទជូនទៅកន្លែងណា»។ លឺសំណួរនេះគេពិបាកឆ្លើយដូចជនជាប់ចោទបទឧក្រិដ្ឋ ត្រូវគេអោយឆ្លើយសារភាព

www.elibraryofcambodia.org

Scanned with CamScanner

នៅតុលាការ ។ ដោយគ្មានតែបុរសក្មេងម្នាក់នោះដឹកគាត់ពុំហើយ ស្រាប់តែត្រីចក្រ បានសួរសំណួរដដែលនេះម្ដងទៀត ។

បុរសក្មេងខំសំរួលដង្ហើមឆ្លើយម្ដងៗ : "ទេ ឪពុកអើយ ខ្ញុំបាត់ស្លុតខ្លួន ប្អូនស្លឹកឈើដាច់ចាកមែក ខ្សែដាច់ខ្សែងវ័រភាគ...ធ្វើម្ដេចនឹងដឹងត្រូវធ្លាក់នៅទីណា ជនផ្សងព្រេងធ្វើម្ដេចនឹងដឹងទិសដៅ ក្នុងដំណើរហោះរសាត់ ផែលោកណ្ដាលទីក្រុងជាលើកដំបូងនេះ ខ្ញុំបានមកទីរលើត្រីចក្រយានឪពុកហើយ តែងតែគ្មានទីដៅដដែល លោកឪពុកដឹកកូនយកទៅចោលនៅកន្លែងណាក៏បានដែរ..."។

ទុរគតជនភ្ញាក់ផ្អើលយ៉ាងខ្លាំងចំពោះអ្នកជិះម្នាក់នេះ ។ គាត់ឧទាន : "ជនកំសត់អើយ អ្នកជាអ្នកផ្សងព្រេងឬ..." ។ គាត់ដកដង្ហើមធំរួចបន្ត : "ហ៊ឺ!...នៅទីក្រុងមានអ្វីប្រសើរទៅ" ។

ត្រីចក្រយានវិលកង់ទៅមុខយឺតៗ ។ ដើមក្ងោកគ្មានផ្កានៅអមសងវិថីហាក់ទ្រមឹងទ្រមើយបញ្ជាក់នូវការរស់តរង្សី ។ សំលេងយានយន្តអ៊ូអែក្នុងទីក្រុងហាក់ព្រួតគ្នាសើចចំអកអោយបុរសផ្សងព្រេងម្នាក់នេះ ។ ទឹកមុខគេប្រែពោនស្រពាប់ ក្នុងចិត្តតែនព្រួយបារម្ភចំពោះវាសនាអនាគតរបស់ខ្លួន។

តាមការដេញដោលសួរ បុរសចំណាស់ដឹងរស់រាទីសេចក្ដីនៃការផ្សងព្រេងនេះ ។ ដើមហេតុនៃការចាកចេញពីស្រុកភូមិមកផ្សងព្រេងរកការងារធ្វើនៅទីក្រុងរបស់គេ ដូចដើមហេតុនៃការចាកចេញពីកំពង់ចាមមកទីក្រុងរបស់គាត់កាលពីដប់ឆ្នាំមុនដែរ ។ ឆ្លងកាត់ពេលវេលា បទ

www.elibraryofcambodia.org

Scanned with CamScanner

ពិសោធន៍នៃលំបាក គាត់មិនចង់អោយនរណាម្នាក់ផ្សេងទៀតដូចគាត់ ឡើយ ពិសេសអ្នកនៅចំពោះមុខគាត់បង្កើយនេះ។ គាត់នឹកសង្វេគអាណិត អាសូរគេដូចកាប់ឈាមរបស់ខ្លួន ។ ក្នុងន័យយកចិត្តទុកដាក់ចំពោះត្រង់ គាត់ពោលបណ្ដែនាំគេដូចឪពុកណែនាំកូន : កូនឪពុកអើយ! ផ្លូវដែលកូន ប្រុងដើរនេះ ឪពុកបានដើរឆ្លងកន្លងមកអស់កាលប្រមាណដប់ឆ្នាំហើយ។ ពេលនេះចូរកូនក្រឡេកមើលមកពុក តើគួរអោយត្រេកអរសប្បាយជាមួយ ណាស់ឬ ក្នុងសំលៀកបំពាក់ចាស់ពព្វក់ រូបកាយស្គមស្គាំងត្រែកត្រស្រព ដោយតំណក់ញើស! ការលំបាកនៅតែលំបាក ភាពក្រីក្រនៅតែក្រីក្រ ដដែល...។ ហ៊ឺ...បានស្គាល់កូនហើយពុកមិនចង់ឃើញមានជីវិតដូចពុក ទេ កូនគួរត្រលប់ទៅស្រុកខិតខំធ្វើស្រែចំការវិញជាការណ៍ប្រសើរជាង ។ ពេលនេះមិនទាន់ហួសពេលទេ សូមកូនគិតពិចារណាជាថ្មីឡើងវិញ ។

យុវសេតបរិញ : ឪពុកអើយ! កូនសូមអរគុណចំពោះការណែនាំនេះ ប៉ុន្តែព្រានព្រៃចូលដល់ចាត់ព្រៃហើយ ទោះដឹងក្នុងព្រៃអស់សព្វសត្វក៏គង់ ចូលទៅអោយអស់ចិត្តដែរ ។ កូនចេញពីស្រុកហើយមិនចង់ត្រលប់ ទៅវិញទេ ទុកអោយកូនបានរែកពន្លងជីវិតដូចឪពុកនេះចុះ! ត្រលប់ទៅ វិញឃើញតែស្រែស្រូវអត់ទឹក កូនលំបាកចិត្តជាងលំបាកចិត្តក្នុងជីវិតផ្សងព្រេង នេះទៅទៀត ។ ឪពុក! ដាក់កូនចុះត្រឹមនេះ ឬកន្លែងណាមួយក៏បាន កូន នឹងបន្តដំណើរផ្សងព្រេងរបស់កូនទៀត ។

ទុគ៌តជនវ័យចំណាស់យល់ពីអារម្មណ៍ជនរសាត់អណ្ដែតរូបនេះ គាត់

www.elibraryofcambodia.org

មិនហ៊ានផ្តល់ឱវាទដល់គេយ៉ាងណាទៀតទេ ។ គាត់កាន់តែអាណិតគេខ្លាំងឡើង ។ វត្តមានបុរសក្មេងនេះរំលឹកគាត់អោយនឹកដល់សំលាញ់របស់គាត់ដែលទើបតែលារូបគាត់ទៅសំរាកក្នុងមឈូស រួចបរិច្ចាគជាចំណីព្រះអគ្គី ព្រោះសំលាញ់គាត់នោះជាអ្នកតាកែវដូចបុរសក្មេងនេះដែរ ។

គាត់នឹកស្រមៃមិនអើបដល់សំលាញ់ ដែលជាអ្នកមានគុណជួយយកអាសាគាត់ ។ ពេលនោះគាត់មកផ្សងព្រេងរកការងារធ្វើនៅភ្នំពេញ ហើយចៃដន្យបានជួបសំលាញ់គាត់ប្រកបដោយចិត្តសប្បុរស ជួយគាត់អោយមានរបរជាអ្នកធាក់ត្រីចក្រយានជាមួយគ្នា ។ សំលាញ់គាត់ថែមទាំងទុកចិត្តទុកជ្រើមអោយគាត់ទៅស្នាក់នៅផ្ទះជួលជាមួយគ្នាទៀតផង ។

ក្នុងការរួមរស់កំសត់កំរជាមួយគ្នានោះ ពួកគាត់ស្រឡាញ់ស្មោះត្រង់ចំពោះគ្នា ហើយមិនដែលមានបញ្ហាអ្វីធ្វើអោយរអាក់រអន់ចិត្តគ្នាទៅវិញទៅមកនោះទេ ។ សំលាញ់គាត់ផ្តល់ភាពកក់ក្តៅដល់ជីវិតឯកោរបស់គាត់ជំនួសប្រពន្ធកូនគាត់ដែលនៅឆ្ងាយ ។

គាត់នៅចាំមិនភ្លេចឡើយ ជារឿយៗក្នុងពេលរាត្រីមុនពេលបិទភ្នែកនាំគ្នាសំរាន្ត សំលាញ់គាត់តែងតែច្រៀងអោយគាត់ស្តាប់នូវបទយីកេ ។ សំលាញ់គាត់ច្រៀងយីកេពីរោះណាស់ សក្តិសមជាអ្នកមានដើមកំណើតនៅខេត្តតាកែវជាខេត្តប្រភពកំណើតសិល្បៈយីកេ និងជាខេត្តដែលល្បីល្បាញខាងសិល្បៈប្រភេទនេះ ។

មានបទមួយដែលសំលាញ់គាត់ច្រៀងអោយគាត់ស្តាប់ញឹកញាប់ជាង

www.elibraryofcambodia.org

គេតែងបទដែលបង្ហាញនូវមនោសញ្ចេតនា និងមោទនភាពរបស់សំលាញ់គាត់ចំពោះស្រុកកំណើតតាមចំណងជើងថា បុរីគោកធ្លក ។ បទចំរៀងនោះពោលទំនុកថា :

គោកធ្លកបុរីទឹកដីកំណើត កន្លែងកកើតជាតិកម្ពុជា
ព្រះថោងនាងនាគក្សត្រដើមឈ្មោះយករ ទុកកេរសោភាជាទំនៀមល្អ។
-គោកធ្លកកោកេរដែនដីបវរ ប្រាង្គប្រាសាទថ្មឆ្លាក់ក្បាច់មានយស
ចំរៀងភ្លេងការចាប៉ីពីរោះ បើកល្បីល្បោះល្បាសាក់ក្ដីខ្លួន ។
-សិប្បករល្អក្រៃមុំមានក្បួន តម្បាញខ្ជាប់ខ្ជួនញាប់ជើងដៃ
ហូលព្រែក្រអាផាម្លូងល្អក្រៃ គយគន់ឆ្មើមឆ្មៃគាប់ចិត្តរសិកក៏។
-តាកែវទំនាបវាលរាបវាលស្រែ ត្នោតដុះរៀបរាបៃតងខ្ចីឆ្ងាយជិត
អ្នកស្រុកសុខសាន្តបានគ្រប់ជីវិត គួរចង់រស់ពិតជិតគូសង្សារ ។

នឹកឃើញចំណងមិត្តភាពដ៏ល្អរវាងរូបគាត់ និងសំលាញ់គាត់ធ្វើអោយគាត់រំភើប ចង់ភាវនានៅជាមួយបុរសក្មេងនេះដែរ ។ រូបគេជាអ្នកមកជំនួសអោយគាត់នូវសំលាញ់គាត់ដែលមរណភាពដណ្ដើមយកទៅបាត់នោះ ។

ញើសហូរដោយក្ដៅសតែតសប្បាយចិត្ត ទុរគតជនបានបញ្ជាត្រីចក្រយានទៅឈប់នៅមុខផ្ទះតៀមតូចមួយក្បែរប្រឡាយបង្ហូរទឹកស្អុយ ជាតំបន់អ្នកក្រីក្ររស់នៅ ។ គាត់សំរេចចិត្តយកអាសាអ្នកផ្សេងព្រោះវាក្មេងដូចដែលសំលាញ់គាត់ធ្លាប់ជួយយកអាសាគាត់ដែរ ។ គាត់អោយគេស្នាក់នៅជាមួយគ្នាក្នុងផ្ទះដដែល ដែលគាត់ធ្លាប់ស្នាក់នៅជាមួយសំលាញ់គាត់ពីមុន

www.elibraryofcambodia.org

Scanned with CamScanner

ព្រមទាំងសន្យានាំគេទៅរកផ្ទះពេទ្យក្រីក្រករកានអោយគេដាក់ទៀតផង ។

ក្នុងពេលកំពុងនៃពាក្យពោលដូចផ្សែងអណ្ដែតក្រៃតែតាមខ្យល់ បុរសវិកលការស្រក់ស្រពោនទឹកភ្នែក លើកដៃគំពះថ្លែងអំណរគុណដល់ជនចិត្តសប្បុរស ។ គេពោល ៖ ឪពុកអើយ! អ្នកសប្បុរសណាស់ ខ្ញុំនឹងគោរពអ្នកដូចឪពុកបង្កើតរបស់ខ្ញុំ។

ធ្វើជាកម្មករទាក់ត្រីចក្រយានបុរសដែលធ្លាប់ស្គាល់ជំនាញតែខាងកាន់កោអមន្ត្រីម្នាក់នេះ មានសភាពដូចគោទើបចូលនឹមដំបូង ដូចបក្សីទើបដុះស្លាបរៀនហើរ ។ គេទៅចាំរកម៉ូយនៅឯចំណតរថយន្ត ។ មានអ្នកដំណើរចុះពីរថយន្ត និងអ្នកចេញពីក្នុងផ្សារដាហូរហែត្រូវអ្នកទាក់ត្រីចក្រយាន និងអ្នករត់ទោចក្រយានយន្តឈ្លបប្រជែងគ្នាហៅជិះយានរបស់ខ្លួនទៅកាន់គោលដៅផ្សេងៗ ។ ដោយម្យ៉ាងតែកម្មករត្រីចក្រយានថ្មីដោយសារតែគេមិនប៉ិនប្រសប់ក្នុងការបញ្ចុះបញ្ចូលអ្នកជិះ ម្យ៉ាងគេមិនរហ័សរហួន និងមិនចេះប្រជែងនឹងអ្នកឯទៀតផង ត្រូវគេដណ្ដើមយកម៉ូយអស់។

តាំងពីព្រឹករហូតដល់ថ្ងៃត្រង់ ពុំមានអ្នកដំណើរណាម្នាក់ស៊ូគ្រជិះត្រីចក្រយានរបស់គេឡើយ ។ ក្រោមកំដៅថ្ងៃពោរពេញដោយការហេវហត់ និងមានញើសហូរជោកខ្លួន គេស្រាយក្រមាពីចង្កេះមកអកជូតញើស ។ ផ្ទៃមុខគេស្រពោនស្រពាប់ប្រៀមព្រួយដូចស្លឹករុក្ខជាតិក្រៀមស្វោកដោយកំដៅថ្ងៃ ។

ថ្ងៃក្រោយៗមកទៀតគេអាចរកម៉ូយបានតិចតួចបំផុត ។ ក្នុងមួយ

www.elibraryofcambodia.org

Scanned with CamScanner

ថ្ងៃៗប្រាក់ដែលបានពីការបញ្ចេញញើសរបស់គេយកទៅទិញបាយទទួលទានរួចនៅសល់បន្តិចបន្តួចប៉ុណ្ណោះ ។ មានថ្ងៃខ្លះគេរកប្រាក់មិនបាន សំរាប់ទិញបាយហូបផង ។

ក្នុងស្ថានភាពលំបាកលំបិនបែបនេះ ម្ចាស់ផ្ទះជួលរបស់គាត់តែងតែខេះបារ៉ាចែករំលែកអាហារអោយគេទទួលទាន ព្រមទាំងសន្យាមិនអោយគេជួយចេញថ្លៃឈ្នួលផ្ទះទៀតផងនៅខែដំបូងនេះ ។ តាមការណ៍ពិតរូបគាត់ក៏មិនប្រសើរជាងគេប៉ុន្មានដែរ តែសភាពជីវិតក្រនេះគាត់ធ្លាប់ដឹងអស់ទៅហើយ ។ គាត់អាណិតអាសូរគេពន់ពេកមិនអាចមើលនឹងភ្នែកបានឡើយ ។ លើសពីនេះគាត់ជួយពន្យល់ណែនាំគេអោយប្រឹងតស៊ូតទៅទៀត ។

ជីវិតក្នុងក្រុងកំសត់ធ្វើអោយការព្រួយនឹកត្រូវលោកខ្លួនកាន់ខ្លាំង ។ ពេលនេះការលំបាកជាងពេលណាៗទាំងអស់ ។ គេបារម្ភខ្វល់ខ្វាយក្នុងចិត្តពេកពន់ប្រមាណ ការអត់បាយបរិភោគអាចទទួលបានការដាក់ទានពីជនកំសត់ក៏រងាម្ហូបផ្គា ប៉ុន្តែការអត់ប្រាក់ផ្ញើទៅអោយប្រពន្ធកូនជារឿងឈឺចាប់បំផុតហើយដោះស្រាយមិនចេញ ។ ការអត់ប្រាក់បង់អោយថ្លៃឈ្នួលត្រីចក្រ កានធ្វើម្តេចគេនឹងអនុគ្រោះអោយ ។

រៀងរាល់ថ្ងៃគេទិញអាហារថោកៗយកមកបរិភោគ ។ កាលនៅផ្ទះម្ហូបចំអិនដោយដៃភរិយា ទោះជាម្ហូបបែបស្រុកស្រែតែរួមផ្សំនឹងការទទួលទានជួបជុំក្រុមគ្រួសារផង ពិតជាមានឱជារសឆ្ងាញ់ពិសា ផ្ទុយទៅវិញអ្នក

www.elibraryofcambodia.org

Scanned with CamScanner

ទំនៀមគេតាមចិញ្ចឹមថ្នាក់ថ្នមប្រែជួនលាប គេត្រឹងលេបកុំអោយការតែឃ្លាន ប៉ុណ្ណោះ ។

ទទួលទានពេកណាក៏គេរអួលដើមករហើងពោងទឹកភ្នែកដែរ ។ គេស្រណោះខ្លួនដែលធ្លាក់ក្នុងស្ថានភាពបែបនេះ ។ គេនឹកតូចចិត្តនឹកខ្មាសខ្លួនឯងដែលប្រឆាំងប្រពន្ធ ប្រឆាំងឪពុកពេកចោលស្រុកមករកព្រះប្ដូរផ្ដាច់ផ្ដល់ ត្រួតការ ជួយទៅវិញពីមួយថ្ងៃទៅមួយថ្ងៃរកបានគ្រាន់តែចិញ្ចឹមក្រពះខ្លួនឯងស្ទើរពុំគ្រប់ ។

ដូចអ្នកមិនចេះហែលទឹកលិចទូកកណ្ដាលទន្លេ ជួយខ្លួនឯងស្ទើរពុំរស់ផង ធ្វើម្ដេចអាចជួយសង្គ្រោះអ្នកដទៃបាន បុរសព្រាត់ប្រពន្ធឃ្លាតឃ្លាង អាត្មាខ្លួនឯងទាំងលំបាកផងធ្វើម្ដេចអាចជួយក្រុមគ្រួសារបាន ។ នឹកឃើញនិប្បន្នានឪពុក សំដីពន្យល់ណែនាំរបស់ប្រពន្ធគេកាន់តែតូចចិត្តខ្លាំងឡើង ។

កាលណាគេកាន់តែលំបាកចិត្ត គេកាន់តែនឹកអាឡោះអាល័យដល់អ្នកដែលធ្លាប់សំរើងគេដោយស្និទ្ធស្នេហា កូនទាំងទ្វេ ព្រមទាំងលោកឪពុក។ គេទទួលអារម្មណ៍ដូចជនកំពុងវង្វេងក្នុងរាត្រីងងឹតឈ្លប់ ដូចជនពិការភ្នែកព្រឹងវង្វេងដោយគ្មានអ្នកដឹកដៃ ។ វាំងននអន្ធការបាំងបិទវនសាគេគេមិនអោយឃើញពន្លឺរស្មី ដូចរាត្រីមើលមិនឃើញដួងខែ ពេលព្រួយសំរាកក្នុងលំនៅរនោច ។ ពេលវេលាដឹកដៃគេចេញផុតរង្វើតកាល តែមិនបាននាំគេគេចផុតពីការលំបាកវេទនាយ៉ាកឡើយ។ មិនមែនដោយការលំបាកម៉េចនេះ ដោយក្តីអាឡោះអាល័យដល់ក្រុមគ្រួសារ ពេលខ្លះគេចង់ត្រលប់ទៅផ្ទះ

www.elibraryofcambodia.org

Scanned with CamScanner

វិញភ្លាម ប៉ុន្តែមានតែសំបកខ្លួនទទេក្បាលវាដួលជាក្រវាក់ទាក់ជើងគេមិនអោយរួចទៅណាបាន ។

បុរសចំណាស់សម្បុរសដឹងពីអារម្មណ៍រំភើបរបស់គេ តែងតែព្យាយាមលួងលោមអោយប្រឹងតស៊ូតទៅទៀត ។ គាត់ពោលថា : កូនកំសត់អើយ! អ្នកមានដេកលើគ្រែពូកក្នុងភូមិគ្រឹះមានម៉ាស៊ីនត្រជាក់ អ្នកក្រដេកលើគ្រែនោបឬស្បៃក្នុងខ្ទមធ្លុះធ្លាយ អ្នកមានចាយប្រាក់ដូចក្រដាស អ្នកក្រស្ទើររកមួយសេនចាយគ្មាន អ្នកមានរស់ក្នុងសុភមង្គល អ្នកក្ររស់ក្នុងទុក្ខ...វាជារឿងធម្មតា តើមានអ្វីប្លែកទៅ! នេះហើយជាជីវិត! ចូរកូនប្រឹងតស៊ូប្រយុទ្ធនឹងសត្រូវ ទោះដឹងថាមិនអាចយកឈ្នះគេបានក្តី ប្រសើរជាងកំសាកទន់ខ្សោយអោយគេវាយប្រហារតាមចិត្ត ។ មានជីវិតត្រូវតែមានការតស៊ូ កូនអើយ! កុំតក់ស្លុតបាក់ស្បាតនឹងឧបសគ្គ...។

ទឹកកាន់តែហូរទៅឆ្ងាយ ពេលវេលាកាន់តែទៅមុខឥតងាកក្រោយ ។

វស្សាកាន់តែរំកិលទៅក្នុងរដូវ ។ អាកាសនៅតែបង្ហាញភាពស្រឡះស្រឡំ ពុំមានភ្លៀងមួយតំណក់សោះ ។ សំណាបសន្ទូងកាន់តែស្រពោនទៅ។ ពួកគេប្រឹងយំឡើងរីងទឹកភ្នែកខំស្រែកសូមទឹកភ្លៀងពីមហាមេឃឡើងខះកទៅហើយនៅតែមេឃមិនអាណិតទៀត ។

នារីដ៏ស្លូតបូតទោះបីក្នុងចិត្តពោរពេញដោយទុក្ខព្រួយ ការឈឺចាប់ ការខ្វល់ខ្វាយ ការអាឡោះអាល័យ ការខ្លោចផ្សា...ព្រោះតែស្វាមីចុះចោលដោយគ្មានដំណឹងក្តី នាងនៅតែមានកំលាំងចិត្តក្នុងការធ្វើការងារស្រែចំការ

www.elibraryofcambodia.org

Scanned with CamScanner

របស់នាង ។ កណ្ដាលវាលស្រែគឺសម្ងួតហួតហែង ក្រោមកំដៅថ្ងៃក្ដៅខ្លាំង នាងច្រូតអង្គុយស្ទូងដោយការពារពីព្រានពាហ៍ផ្នួយទាំងហាក់នឿយ ហើយហួរអាកាស ។ នាងយកឈើគ្រាន់ច្រូតស្រូវរឹង រួចទើបដោតសន្ទូង ។ ការងារចំបាពកនេះមានសភាពវេទនាបំផុត មិនដូចការស្ទូងក្នុងស្រែដែលមានទឹកនោះទេ ។

នៅវាលស្រែងទៀតកសិករក៏ច្រូតស្ទូងដូចគ្នានេះដែរ ។ អ្នកស្រែទាំងនេះច្រូតស្ទូងទាំងដៀងព្រៃ ប៉ុន្តែពួកគេសង្ឃឹមមេឃនឹងបង្អុរភ្លៀងនាពេលខាងមុខ ។ ពួកគេមិនមានសង្ឃឹមអ្វីក្រៅពីមេឃទេ ព្រោះតំបន់នេះគ្មានប្រភពទឹក និងប្រព័ន្ធធារាសាស្ត្រល្អប្រសើរ ។

នារីកំព្រាត្បាក់ច្រូតស្ទូងរហូតដល់ថ្ងៃត្រង់។ នាងដើរឈរសំលឹងសន្ទូងដែលទើបស្ទូងរួចទាំងទឹកមុខស្រពោនក្រៀមក្រំ។ នាងខំច្រូតបញ្ចេញកំលាំងអស់ម្ដងព្រឹកហើយលទ្ធផលស្ទូងបានតែលើដីក្នុងទំហំតូចប៉ុណ្ណោះ ។

នាងឈរងើយមើលទៅលើមេឃរួចលើកដៃសំពះអង្វរថា : "ឱ! មេឃអើយ! សន្ទូងសំណាបទាំងឡាយកាន់តែស្វិតស្រពោនឈានទៅងាប់អស់ក្នុងពេលមិនយូរប៉ុន្មាននាគ្រាខាងមុខនេះហើយ ដោយស្ដួងចិត្តសន្ដោសអាណិតអាសូររបស់អ្នកសូមអ្នកបង្អុរភ្លៀងចុះមក ។ កសិករចាត់ទុកអ្នកជាអ្នកមានគុណស្មើជីវិត សូមអ្នកកុំធ្វើអោយពួកយើងអស់សង្ឃឹម ពួកយើងសូមផ្ញើក្ដីសង្ឃឹមលើអ្នកហើយ បើមិនដូច្នោះទេពួកយើងខ្ញុំនឹងដាច់ពោះស្លាប់មិនខាន ។ សូមអ្នកបង្អុរភ្លៀងនាគ្រាឥលូវនេះមក ។

www.elibraryofcambodia.org

Scanned with CamScanner

នារីកសិករីកក្មេងលុតជង្គង់ចុះដោយមិនខ្វល់ពីកំដៅថ្ងៃ ។ នាងគិតថាពាក្យមរណៈការអង្វរកររបស់នាងនេះអោយនឹងទន់ចិត្តអាណិតនាង ព្រោះទាំងកសិករឯទៀត ហើយភ្នែកក្រឡោងក្រហែងក្រហមភក ។ អស់មួយសន្ទុះ មេឃក្ដៅនៅតែក្ដៅដូចខឹងនឹងអ្វីមួយ មិនមានភ្លៀងធ្លាក់មកសូម្បីតែមួយតំណក់ណាឡើយ ។ មេឃធ្វើមិនដឹងមិនលឺការទទូចអង្វរកររបស់នារីម្នាក់នេះទេ ។ មេឃពុំមែនជាសាច់ញាតិរបស់អ្នកភូមិនេះទេ ។ មេឃពុំមានមនោសញ្ចេតនាទេ ... ។

ដោយការអស់សង្ឃឹម ដោយការខឹងចំពោះមេឃ នាងងើបឈរឡើងវិញ សំលឹងទៅមេឃទាំងក្ដាប់មាត់ ។ ការខឹងយ៉ាងខ្លាំងនេះធ្វើអោយនាងយំ ហើយនាងប្រឹងស្រែកជេរទៅមេឃ : -អាមេឃអប្រិយ! មេឃកំណាច! អាមេឃឫស្យា! អាមេឃឃោរឃៅ! មេឃអយុត្តិធម៌...អ្នកជាអ្នកបំបែកប្ដីខ្ញុំទៅឆ្ងាយ! ខ្ញុំពុំសុខចិត្តទេ! អ្នកប្រគល់ប្ដីអោយខ្ញុំវិញមក! អ្នកស្លាប់វិនាសពីលោកនេះទៅ!-។

ទោះជានាងប្រឹងស្រែកជេរយ៉ាងនេះក៏ដោយ មេឃនៅតែធ្វើមិនដឹងមិនលឺដដែល "។ ពួកឧក្រិដ្ឋខ្មែរក្រហមធ្វើទារុណកម្មប្រជាពលរដ្ឋស្លូតត្រង់ដោយគ្មានកំហុសយ៉ាងណា មេឃធ្វើទារុណកម្មកសិករដោយគ្មានកំហុសយ៉ាងនោះដែរ ។

* *

*

តែងវគ្គនេះនៅរាត្រីទី១៩ ខែកញ្ញា
ចប់នៅរាត្រីទី២៤ ខែកញ្ញា ឆ្នាំ២០០៨
ម៉ោង១១ និង២០នាទី

www.elibraryofcambodia.org

Scanned with CamScanner

វគ្គ៣-ស្រណោះខ្លួន

ឪពុកអើយ! អ្នកមកដល់ផ្ទះវិញហើយមែនទេ?

អ្នកដ៏មានគុណសូមកុំរង់ចាំមើលផ្លូវកូនអីណា៎ យប់នេះ ថ្ងៃស្អែក ខានស្អែក... ជនទាល់ច្រកម្នាក់នេះសូមគោរពលាឪពុកតាមរយៈអក្សរនេះហើយ ។ មុនឪពុកមកដល់កូនបានចាកចេញទៅ កូនមិនហ៊ាននៅជួបឪពុកសំពះសុំលាដោយផ្ទាល់ក្នុងភាពទន់ខ្សោយបែបនេះទេ ម្យ៉ាងកូនខ្លាចឪពុកយកបញ្ហារបស់កូនទៅជួយដោះស្រាយទៀត វានាំតែលំបាកដល់ឪពុកខ្លាំងឡើង ។

តាមពិតកូនស្រលាញ់ កូនគោរព ហើយអាឡោះអាល័យពុកក៏ពាំងខ្លាំង ប៉ុន្តែគឺមកពីកូនត្រូវគេរឹបអូសយកត្រីចក្រយានវិញ ដោយសារតែកូនគ្មានលុយគ្រប់គ្រាន់បង់ថ្លៃឈ្នួលខែទីពីរនេះ ។ កូនបានអង្វរម្ចាស់គេសុំអធ្យាស្រ័យអោយកូនជំពាក់ខ្លះក្នុងរយៈពេលខ្លី គេមិនមេត្តាឡើយ ផ្ទុយទៅវិញកូនដឹងច្បាស់ឪពុកនឹងមេត្តាកូន ជួយដោះស្រាយអោយកូន ប៉ុន្តែកូនមិនចង់បែបនេះឡើយ កូនជំពាក់គុណឪពុកច្រើនណាស់ហើយ! ។

www.elibraryofcambodia.org

Scanned with CamScanner

ឪពុកជាទីស្រឡាញ់! អំពើសប្បុរសទាំងឡាយរបស់ឪពុកមកលើកូនបងចាំ និងបឹងគុណរាមិនភ្លេចឡើយ! ថ្ងៃណាមួយកូននឹងតបស្នងឪពុកវិញ! ពេលនេះកូនសូមលាឪពុកបន្តដំណើរផ្សងព្រេងតទៅទៀតហើយ កូនមិនដឹងថាត្រូវទៅកន្លែងណាច្បាស់លាស់ទេ!

សូមលោកឪពុករស់នៅអោយបានសុខណា៎! កូនសូមលាហើយ!

ពីកូនសែន រសាត់

អានចប់បុរសចំណាស់ទុរគតបិទសំបុត្រវិញទាំងដៃញ័រទទ្រើតដោយក្តីអាណិតអាឡោះអាល័យដល់រសាត់ គាត់ស្រក់ទឹកភ្នែក ។ ផ្ទះដែលធ្លាប់រួមរស់ជ្រកកោនកំសត់កំព្រានាក់ ពេលនេះនៅសល់តែគាត់ម្នាក់ឯងឯកា ជាមួយពិរិឌិតដែលម្ចាស់វាឃ្លាតឃ្លាចេញទៅគ្មានបញ្ជាក់គោលដៅច្បាស់លាស់ ។

ជនសប្បុរសចង់ទៅតាមរកគេ បោក្រលប់មកនៅជាមួយគាត់វិញ ប៉ុន្តែគាត់គ្មានសង្ឃឹមនឹងតាមរកឃើញឡើយ ។ ដំណើរផ្សងព្រេងរបស់គេដូចពពករសាត់អណ្តែតក្នុងវេហាអាកាស ។

ឈរស្ទៀរស្ទោចផ្សារដោយទុក្ខវិយោគមួយសន្ទុះ គាត់ផ្គុំដៃលើកតម្កើងសម្លឹងទៅមេឃ : "ឱ! ជនផ្សងព្រេងអើយ ពុកអាណិតកូនណាស់ សូមទេវតាជួយកូនអោយជួបតែសំណាងល្អ..."។

រសាត់មានគំនិតចង់ធ្វើជាកម្មករសំណង់វិញម្តង ។ គេបានដើរចូលទៅក្នុងការដ្ឋានសំណង់ផ្ទះវីឡាធំមួយ ហើយទំនាក់ទំនងជាមួយកម្មករ

www.elibraryofcambodia.org

Scanned with CamScanner

ម្នាក់សួររកមេការនៅទីនោះ ។ តាមរយៈការចង្អុលបង្ហាញគេបានដើរទៅជិតមេការមាឌធំខ្ពស់ស្លៀកពាក់ហ៊ីហា រួចលើកដៃសំពះជំរាបសួរ ។ មេការសំលឹងសោត៍ក្នុងក្រសែភ្នែកមិនពេញចិត្តរាប់អានអ្វេស ហើយនិយាយទាំងគំរោះគំរើយ : "ឯងមកជួបអញមានការអី?"។ វេភាត់ប្រញាប់ឆ្លើយ : "លោកម្ចាស់! ខ្ញុំបាទជាអ្នកទីទាល់ក្រមកពីទីជនបទ រាប់តែចិត្តសន្ដោសរបស់លោកម្ចាស់ សូមលោកម្ចាស់មេត្តាអនុគ្រោះអោយខ្ញុំបាទបានធ្វើការនៅទីនេះផង!"។ មេការសួរ : "ឯងចេះរៀបគ្រឿងទេ?"។ "ខ្ញុំបាទអត់ចេះទេលោកម្ចាស់"វេភាត់ឆ្លើយ ហើយមេការសួរទៀត : "ចុះឯងចេះលាយស៊ីម៉ង់ត៍ទេ?"។

វេភាត់នៅអត់មាត់មួយស្របក់ទើបឆ្លើយទាំងលើកដៃសំពះមេការ : "រឿងនេះក៏ខ្ញុំបាទអត់ចេះធ្វើដែរ! លោកម្ចាស់? ខ្ញុំបាទមានរូបកាយធំមាំ កំលាំងកំហែងខ្លាំងក្លា អ្វីដែលខ្ញុំបាទមាននេះសូមលោកម្ចាស់អាណិតអាសូរទទួលអោយខ្ញុំបាទនៅបំពេញកិច្ចការលីសែង ឬអ្វីក៏បានដែរ អោយតែបានប្រាក់កំរៃខ្លះ ។ សូមលោកម្ចាស់មេត្តាអាណិតអាសូរដល់ខ្ញុំបាទផង!"។ មេការសំឡក់មើលមុខហើយនិយាយគំរោះគំរើយ : "គ្រាន់តែលាយស៊ីម៉ង់ត៍មិនចេះផង ចង់មកធ្វើការសំណង់ ពេញៗ! ឯងទៅអង្វរដើររកកន្លែងផ្សេងទៅក្រែងមានសំណាង"។ មេការនិយាយទាំងញោះជិហានដើរចេញពីវេភាត់ ។

ជនរងគ្រោះបានព្យាយាមទៅសុំគេធ្វើការ នៅការដ្ឋានសំណង់ចំនួនពីរកន្លែងទៀត ប៉ុន្តែលទ្ធផលបរាជ័យដូចមុនដដែល ។ នៅកន្លែងមួយផ្សេងទៀតតាមរយៈការអង្វរកររបស់វេភាត់ មេការមានក្ដីអាណិត

www.elibraryofcambodia.org

Scanned with CamScanner

ទទួលយកគេធ្វើការជាមួយ ។ ដោយគ្មានជំនាញអ្វីសោះលើការងារណាមួយ មេការបានចាត់គេឲ្យធ្វើជាកម្មករជញ្ជូនថ្ម និងកិច្ចការកំប៉ិកកំប៉ុកផ្សេងៗទៀតដែលគេអាចធ្វើបាន ។ ការងារនេះនាងទទួលបានប្រាក់កំរៃក្នុងមួយថ្ងៃចំនួនប្រាំបីពាន់រៀល ។

នាងមិនធ្លាប់ធ្វើការងារធ្ងន់ ហើយទោះជាហត់នឿយយ៉ាងណាក៏ដោយក៏ខំអត់ធ្មត់សង្កត់ចិត្តដែរ ។ ក្នុងមួយថ្ងៃៗគេបញ្ចេញកំលាំងញើសរាប់ម៉ឺនដំណក់ ផ្ទុយទៅវិញគេទទួលទានតិចតួចបំផុត ព្រោះបើមិនសន្សំតែទេប្រាក់កំរៃប្រាំបីពាន់រៀលគ្រាន់តែថ្លៃទិញបាយទទួលទានស្ទើរពុំគ្រប់ផង។

ពីណាក់កាលនេះ អាហារឆ្ងាញ់ៗលែងសំខាន់សំរាប់គេទៅហើយ។ គេក៏មិននឹកនាដល់ដែរ បញ្ហាដែលធំបំផុតគឺគេត្រូវធ្វើយ៉ាងណាក្នុងមួយថ្ងៃនោះនៅសល់ប្រាក់ខ្លះសំរាប់ទុកសន្សំផ្ញើទៅរកប្រពន្ធកូននៅឯស្រុក។

កាលពីនៅផ្ទះនាកគេមានខ្នើយ មុង កន្ទេល ព្រមទាំងប្រពន្ធកូនពោរពេញដោយការកក់ក្ដៅ ផ្ទុយទៅវិញនៅការដ្ឋានសំណង់នោះព្រះធរណីក្លាយជាគ្រែ ស៊ីបកប្រាវស៊ីម៉ង់ត៍ក្លាយជាកន្ទេល ឥដ្ឋក្លាយជាខ្នើយ និងក្រមាតូចស្ដើងក្លាយជាភួយរបស់គេ ។ យប់ណាក៏ដូចយប់ណាដែរ គេដេកហាលខ្យល់ហាលមូស ។ គេដេកសង្កុញខ្លួនក្នុងក្រមាទាំងរងាញ័រព្រាណ ។ យប់ខ្លះមានភ្លៀងធ្លាក់គេរងាយ៉ាងខ្លាំងរហូតដេកពុំលក់ហើយអង្គុយអោបដៃសំកុកនៅម្នាក់ឯង ។

តាំងពីគេចាកចេញពីស្រុកកំណើតផ្ទះសំបែង ប្រពន្ធកូនរយៈពេលជាង

www.elibraryofcambodia.org

ពីរខែអាកនេះ គេមិនដែលមានប្រាក់ផ្ញើទៅអោយប្រពន្ធម្ដងណាឡើយ ។ ពីមួយថ្ងៃទៅមួយថ្ងៃគេមើលឃើញការលំបាកកាន់តែមានទំហំធំឡើង ។ ជើងមេឃល្ហល្ហេវក្លាយដាក់តម្លៃងវ៉ែងណា ក្ដីសង្ឃឹមរបស់គេក្លាយជាប់សង្វៀងយ៉ាងនោះដែរ ។

ក្បួនផ្សងព្រេងរបស់គេជួបព្យុះកណ្ដាលសាគរបោកបក់បន្សាត់ទៅទើរលើកោះអស់សង្ឃឹម បង្វែងបាត់ផានកោះក្ដីសង្ឃឹម ។ ភរិយាវង្វេងបាត់ដួងខែរសាត់វង្វេងបាត់ក្ដីសុខក្នុងជីវិត គេសល់តែការខំប្រឹងទាំងលំបាកប៉ុណ្ណោះ ។

រៀងរាល់ថ្ងៃទោះការហត់ហេវត្របសង្កត់លើគេយ៉ាងណាក្ដី នៅតែមិនអាចរំងាប់ការព្រួយពីទុក្ខលំបាក ការនឹកនាអាឡោះអាល័យដល់ក្រុមគ្រួសារបានឡើយ ។ គេដឹងច្បាស់អ្នកទាំងនោះពិតជាអន្ទះសារដងចាំទទួលដំណឹងពីសុខទុក្ខរបស់គេជាងការផ្ញើប្រាក់កាក់ទៅអោយ ប៉ុន្តែគេធ្វើម្ដេចនឹងហ៊ានផ្ដាំផ្ញើ ឬសរសេរលិខិតទៅប្រាប់ បើអ្វីដែលត្រូវរ៉ាយរាប់សុទ្ធតែរឿងកំសត់មិនមែនរឿងសប្បាយបែបនេះ ។ ដួងខែចង់រះបង្ហូតខ្លួនក្នុងរាត្រីប្រកបដោយមេឃស្រឡះស្រទន់នារដូវរងាហើយ មិនមែនក្នុងរដូវវស្សាឡើយ បុប្ផាចង់រីកបង្ហូតសម្រស់នាពេលព្រឹកព្រាង មិនមែនពេលយប់ងងឹតឡើយ ឯរសាត់ចង់ផ្ដល់ដំណឹងពេលជីវិតរុងរឿងសំបូរសប្បាយ គេមិនចង់អោយក្រុមគ្រួសារលំបាកចិត្តទ្វេឡើង ពេលដឹងគេរស់ក្នុងស្ថានភាពទុក្ខព្រួយនេះទេ ។

រសាត់ខ្វល់ខ្វាយទាំងទាល់គំនិតមិនដឹងធ្វើម្ដេច ឬពេលណាមានប្រាក់

www.elibraryofcambodia.org

Scanned with CamScanner

ធ្វើទៅអោយប្រពន្ធទេ បើគេខំធ្វើពលកម្មបញ្ចេញអស់កំលាំងកំហែងពីក្នុងខ្លួនទៅហើយនៅតែមិនបានកំរៃច្រើនទៀតនោះ ។ អាលពេលខ្លះគេត្រូវតែស្រមៃថាបើគេបានលុយកាក់ពេញហោប៉ៅ ធ្វើអោយគេសប្បាយចិត្តយ៉ាងខ្លាំង ហើយគេបានផ្ញើទៅអោយប្រពន្ធកូនទាំងអស់ ។

រុក្ខជាតិប្រភេទខ្លះ តែកាលណាទឹកជន់លិចក្នុងរយៈពេលយូរវានឹងពេញទឹករងាប់ ។ ក្លាយជាស្ងួតតែកាលណាគេដុតដោយដាក់ភ្លើងខ្លាំងពេកវានឹងខ្លោច ។ មនុស្សយើងកាលណាខំធ្វើការហួសកំលាំង គិតច្រើនពេកនឹងបណ្តាលអោយពិការមិនខាន ។ របាត់ធ្វើការសំណង់បានតាំងដល់ថ្ងៃធ្លាក់ខ្លួនឈឺគ្រុនក្តៅយ៉ាងខ្លាំង ។

គេឧកខានមិនបានធ្វើការទៀតឡើយ ។ ប្រាក់ដែលគេសន្សំទុកបានបន្តិចបន្តួច គេយកទៅទិញថ្នាំពេទ្យ ។ គេដេកព្យាបាលខ្លួនដោយខ្លួនឯង គ្មានអ្នកមើលថែ គ្មានការកក់ក្តៅបន្តិចឡើយ ។

វេទនាកំព្រា ហើយថែមទាំងលំបាកក្នុងខ្លួនពេកសោកស្រណោះស្រណោក ខ្លួនហៀតខ្សឹកខ្សួលអួលដើមក ។ ទឹកភ្នែករបស់គេទោះជាហូរយ៉ាងណាក៏មិនអាចត្រូវបានយកអស់នូវភាពខ្លោចផ្សាចំពោះជីវិតរបស់ខ្លួនឯងនេះដែរ ។ ក្មេងកំព្រាគ្មានឪពុកម្តាយរបស់គេល្អង ផ្ទុយទៅវិញបុរសឯកោម្នាក់នេះបាននរណាជួយលួងលោម បើគេរស់នៅឆ្ងាយពីប្រពន្ធកូន ។

ក្នុងស្ថានភាពបែបនេះជនកំព្រានឹកដល់គ្រួសារយ៉ាងខ្លាំង ។ គេនឹកឃើញពេលគេឈឺម្តងៗ នាងតែងតែយកចិត្តទុកដាក់មើលថែទាំយ៉ាងដិត

www.elibraryofcambodia.org

Scanned with CamScanner

ដល់តាំងពីការផ្តល់ថ្នាំសង្កូវការគាក់ព្រាប់ ពិសេសការនិយាយទន់ភ្លន់ផ្តល់កំលាំងចិត្តអោយនោះជា ។ កូនបក្សីព្រាត់មេខ្វះចំណី រសាត់ព្រាត់ប្រពន្ធខកខានមិនបានការថែទាំពីនាងដូចមុនទៀតឡើយ ។ ជំងឺដែលកើតឡើងកាយនោះមិនជាប៉ុន្មានទេឡើយគេអាចទ្រាំទ្របាន ប៉ុន្តែភាពជាខ្វះការយកចិត្តពីអ្នកមើលថៃ វាធ្វើអោយគេទទួលអារម្មណ៍ដូចជាពិបាកទ្រាំយ៉ាងខ្លាំង ។

រសាត់នឹកថាក្នុងគ្រាតែរនទារុណនេះ បើបានការថៃទាំបីបមផ្អែមប្រលោមចិត្តពីកេត្តាទាំងគូនៃនារីកំពូលស្នេហ៍ កំពូលដួងចិត្ត ម្ល៉េះគេនឹងបានសះស្បើយមិនកាំបាច់ត្រូវការឱសថឡើយ ។

ការណ៍ពិតគ្មាននរណាឡើយ គឺបុរសដែលចុះចោលប្រពន្ធនេះហើយជាអ្នកដាក់ទណ្ឌកម្មជីវិតខ្លួនឯងដោយខ្លួនឯង ។ នារីទុក្ខព្រួយមិនបានបោះបង់តួនាទីជាភរិយាដ៏ល្អម្នាក់ឡើយ ប៉ុន្តែនាងបំពេញតួនាទីនេះម្តេចនឹងកើត បើគេទៅបាត់មិនទាំងផ្តល់ដំណឹងផងនោះ ។

ក្នុងយប់ងងឹត បុរសគេងបង្ហូរទឹកភ្នែកពោលម្នាលអាក់ម្នាក់ឯង : អូនសំណព្វចិត្តបងអើយ! បងលំបាកក្នុងខ្លួនណាស់ បងចង់នៅក្បែរអូន ចង់ទទួលការថៃទាំពីអូន ចង់អោយអូនលួងលោមបងអោយលេបថ្នាំ បងពិតជាត្រូវការអូនខ្លាំងណាស់! ប៉ុន្តែ...បងបានធ្វើអោយអូនឈឺចាប់ អូនព្រួយអូនលំបាកណាស់ទៅហើយ បងដឹងខ្លួនទោះជាបងត្រូវការអូនយ៉ាងណា... បងមិនត្រូវនាំការលំបាកនាពេលនេះទៅបន្ថែមអោយអូនទៀតទេ! ជំងឺកំណាច ភាពកំសោយ...ដោយសារការស្អប់ខ្ពើមរបស់ខ្ញុំ ពួកអ្នកចាកចេញ

www.elibraryofcambodia.org

នៅអោយបាត់ពីក្នុងអ្នកខ្ញុំទៅ ហ៊ឺ ប្រពន្ធសំលាញ់បងអើយ បងនឹកអូន ខ្លាំងណាស់ ។

* *

*

តែងវគ្គនេះនៅរាត្រីទី២៩ ខែកញ្ញា

ចប់នៅរាត្រីទី៧ ខែតុលា ឆ្នាំ២០០៥

www.elibraryofcambodia.org

Scanned with CamScanner

៤-ស្រែករហែកមេឃ

ពេលជាសះស្បើយពីភាពអារម្មណ៍នឿយណាយនឹងជីវិតជាកម្មករសំណង់នៅភ្នំពេញយ៉ាងខ្លាំង គេបានសំរេចចិត្តទៅរកនាយឆ្ងាយពីផ្ទះ តែប្រាក់សន្សំតិចតួចបន្ទាប់ពីទិញថ្នាំព្យាបាលជំងឺ គេយកធ្វើសោហ៊ុយធ្វើដំណើរទៅកាន់ទល់ដែនប៉ោយប៉ែត ។ គេធ្លាប់លឺពីមុនមកថានៅទីនោះសំបូរការងារច្រើនដោយកំលាំងដូចជាលីសែង រុញរទេះជាដើម ។

ជិះរថយន្តឈ្នួលទៅដល់ប៉ោយប៉ែត ស្ងាត់ចាំមើលកន្លែងខ្លាំងនឹងសកម្មភាពមនុស្សយ៉ាងអ៊ូអរកកកុញចេញចូលតាមច្រកព្រំដែនខ្មែរ សៀម ។ គេកត់សំគាល់សកម្មភាពជនប្រើកំលាំងខ្លួននឹងប្រាក់ទាំងឡាយ ហើយសញ្ជឹងគិតថាតើមានការងារអ្វីដែលគេអាចធ្វើបាន ។ បើធ្វើអ្នករត់ទោចក្រយានយន្តឈ្នួលគេគ្មានទោចក្រយានយន្ត បើធ្វើអ្នករុញរទេះគេគ្មានរទេះ បើធ្វើកម្មករលីសែងមិនដឹងទៅទាក់ទងអ្នកណា បើគេមកទីនេះក្បាលមួយក្រមង់ក្រមោចគ្មានស្គាល់នរណាម្នាក់សោះនោះ ។

កំពុងតែឈរសញ្ជឹងគិតស្រាប់តែគេប្រទះភ្នែកនឹងប្រុសអ្នករុញរទេះម្នាក់

www.elibraryofcambodia.org

Scanned with CamScanner

ហាក់ដូចជាមនុស្សធ្លាប់ស្គាល់គ្នាពីពេលមុនមក ។ គេដើរទៅជិតកម្មករម្នាក់នោះកើតក្តីអាណិត ព្រោះស្គាល់ច្បាស់ជាអ្នកស្រុកភូមិជាមួយគ្នាឈ្មោះភន្លាត ។

គ្រាជួបជុំគ្នាជាលើកដំបូងនេះ បុរសទាំងពីរស្ទាតមិនភាក់ទាក់គ្នាដោយក្តីអំណរ ព្រោះជាជនក្រីក្រនៅទីក្រុងរីករានឆ្ងាយពីស្រុកភូមិរបស់ពួកគេ។ ជនពនេចរឆ្ងាយពីភូមិកំណើតរបស់ខ្លួន គេក៏បានជួបអ្នកស្រុកជាមួយគ្នាណាស់ ហើយពេលបានជួបម្តងៗ អនោសញ្ចេតនារបស់ពួកគេចំពោះគ្នាពីដូចបងប្អូនបង្កើត ។

ពាក្យចាស់ពោលថា "នៅផ្ទះក្លាយទីទៃនៅព្រៃក្លាយជាគ្រួសារ" ពេលបានស្តាប់ការរៀបរាប់ពីជីវភាពរសាត់អណ្តែតរបស់គេរួច បុរសអូសរទេះជួយករុណាគេនាំគេទៅស្នាក់នៅខ្ទម ដែលជួលគេស្នាក់នៅជាមួយគ្នា ។ មិនតែប៉ុណ្ណោះសំលាញ់ម្នាក់នេះទៅរកជួលរទេះគេអោយគេអូសរទេះជាមួយគ្នាទៀតផង ។

រសាត់ថ្លែងអំណរគុណចំពោះសន្តានចិត្តដ៏ល្អរបស់សំលាញ់ម្នាក់នេះ ព្រោះបើគ្មានគេទេ ម៉្លេះសមគេលំបាកយ៉ាងណាទៀត ។ គេរំជួលចិត្តរហូតហូរទឹកភ្នែកចំពោះទឹកចិត្តសប្បុរសរបស់សំលាញ់គេ ដែលជួយស្រោចស្រង់គេក្នុងគ្រាដែលលំបាកលំបិននេះ ។ គេចាត់ទុកការបានជួបសំលាញ់ម្នាក់នេះ ដូចបានជួបកញ្ចប់សំណាងដ៏ធំមួយនៃក្នុងជីវិត ។

ទោះបីធ្វើជាកម្មករអូសរទេះថ្មីមិនទាន់ស្គាល់កន្លែងកន្លៀត តែរសាត់

www.elibraryofcambodia.org

Scanned with CamScanner

មិនលំបាកណាស់ទៀត ព្រោះមានសន្តានជួយគ្រប់បែបយ៉ាង ។ សន្តានបាន ជួយរៀបការរីកិនដាក់អោយរតភាត់រួស ព្រោះគេប៉ិនប្រសប់ក្នុងការងារនេះ ព្រមទាំងមានកម្មករច្រើនផង ។

ជារៀងរាល់ថ្ងៃពួកគេគេច្រើនរួសទំនិញ ចេញ-ចូលព្រំដែនជិតរាបេន្លា ព្រោះពួកគេរកទំនិញដាក់ពេញជិណាលគ្នាដែរ ។ ពួកគេទាំងពីរនាក់ម្នាក់ៗ សុទ្ធតែមានការអំណត់រត់ចន់នឹងការងារដូចគ្នា ។ ពេញមួយថ្ងៃពួកគេទុក ពេលសំរាកតិចតួចណាស់ ពួកគេស្អប់ពេលទំនេរ ស្រលាញ់ពេលមានការ ងារធ្វើទោះជាពេលវេលាប៉ាត់បែរណាក្តី ។

ក្នុងការសន្សំតាំរ៉ៃ សំលាញ់ទាំងពីរមិនបរិភោគអាហារពេលព្រឹក ឡើយ។ ការកាត់ទំលាប់បែបនេះ ព្រោះពួកគេមិនដឹងថាមនុស្សត្រូវទទួល ទានក្នុងមួយថ្ងៃចំនួនបីពេលឡើយ ។ សេវាតិពេលព្រឹកដែលព្រោះអ្នក ទាំងពីរធ្លាប់ដឹងធ្លាប់ទទួលនោះគឺទឹកមួយកែវ ។ តាំងពីពេលស្នាក់នៅជាមួយ គ្នាដំបូងសន្តានបានណែនាំអោយរតភាត់ផឹកទឹកមួយកែវ មុនពេលចេញទៅ ធ្វើការ ។ គុណប្រយោជន៍នៃទឹកមួយកែវនេះសន្តានប្រាប់សំលាញ់គេថា វាមានថាមពលស្មើអាហារពេលព្រឹកមួយពេលឬបាយមួយចាន ។ សន្តាន និយាយប្រាប់រតភាត់ថា : "សំលាញ់អើយ! ជីវិតជាកម្មករនៅទីនេះរកបាន ព្រឹកខ្វះល្ងាច អាហារពេលព្រឹកវាមានន័យអ្វីទៅ! ទឹកមួយកែវមានតំលៃខ្លាំង ណាស់សំរាប់ពួកយើង។

រាល់ពេលទទួលទានអាហារថ្ងៃត្រង់ និងអាហារពេលល្ងាច សំលាញ់

www.elibraryofcambodia.org

Scanned with CamScanner

ទាំងពីរបានចូលរួមក្រុមគ្នាម្នាក់បន្តិចទិញផ្កាយរស់ពេលមកទទួលទានជុំគ្នា ។ ពួកគេបង្កើតបានសង្គមគ្រួសារមួយក្នុងគ្រាកំសត់ ។ អាហារពេលពេលក៏មានរសជាតិឆ្ងាញ់ដែលសំរាប់ពួកគេ វាមិនដែលមានពេលពួកគេស្រេកឃ្លានហូបមិនចូលនោះទេ ។

ពេលហូបបាយជុំជាមួយសំលាញ់ម្នាក់នេះ រសាត់តែងនឹកដល់ឪពុកធម៌របស់គេនៅភ្នំពេញជានិច្ច ។ គេធ្លាប់កំសត់ក្នុងតែពីរនាក់នឹងគាត់ ដូចជាមួយគន្លាននាពេលនេះដែរ ។ គាត់ចាស់ណាស់ទៅហើយ តាំងពីគេឃ្លាតឆ្ងាយពីគាត់មកមិនដែលបានទទួលដំណឹងពីគាត់សូម្បីតែបន្តិចសោះមិនដឹងគាត់រស់យ៉ាងណាទេឡើយ ។ រសាត់នឹកឧទ្ទិសក្នុងចិត្តថា : "ឪពុកពីសណ្ដោសអើយ សូមអ្នកបានប្រកបតែសេចក្ដីសុខ កុំមានពិរិទ្ធភ័យត្រូវណាបៀតបៀនអោយសោះ ។"

រស់នៅជាមួយគ្នាយូរទៅ អ្នកទាំងពីរកាន់តែស្រលាញ់រាប់អានគ្នាខ្លាំងឡើង ។ ម្នាក់ៗគ្មានទីពឹងគ្មានប្រពន្ធកូននៅក្បែរ ពេលវេលាជាច្រើនឆ្នាំបេរពួកគេយកចិត្តទុកដាក់ថែទាំគ្នាទៅវិញទៅមក ។ ការរាប់អានរវាងបុគ្គលទាំងពីរនេះចំពោះគ្នា វាកើតសាច់សាលោហិតតែមួយទៅទៀត ។ មានអ្នកខ្លះកើតចេញពីផ្ទៃម្ដាយតែមួយ ប៉ុន្តែដោយសារតែរឿងកេរមរតក ឬផលប្រយោជន៍បន្តិចបន្តួចប្រែក្លាយជាគូសត្រូវ ។ អ្នកខ្លះទៀតជាប់សាច់លោហិតជិតនិងគ្នា តែមិនស្គាល់រាប់អានគ្នាធ្វើអោយពួកគេមានគំលាតពីគ្នាជាងអ្នកដទៃទៅទៀត ។

www.elibraryofcambodia.org

មនុស្សមានឈាមពណ៌ក្រហមដូចគ្នា ការណ៍ពិតទៅមិនចាំបាច់តែមានម្តាយ ឪពុករួម ឬជាប់សាច់ឈាមនឹងគ្នានោះទេ ទោះអ្នកដទៃសុទ្ធសាធ ជាតិសាសន៍ផ្សេងគ្នា ភាសាផ្សេងគ្នា... ក៏គេអាចរាប់គ្នាជាបងប្អូនបានដែរ អោយតែត្រូវស្រឡាញ់ស្មោះត្រង់ចំពោះគ្នាទៅវិញទៅមក ។ វេហាត់ និងសន្តាន បាននិយាយសាច់ឈាមទុកគ្នាជាបងប្អូន ។ ជាទូទៅមនុស្សជាប់សាច់សាលោហិតនឹងគ្នាបង្កើតពីម្តាយតែមួយ ឬពីពូជពង្សវង្សត្រកូលរបស់គេ រ៉ុន្តែវេហាត់ និងសន្តានបង្កើតពីមនោសញ្ចេតនាស្រលាញ់រាប់អានគ្នាស្មោះត្រង់ ។

រដូវភ្លៀងធ្លាក់ជិតបញ្ចប់ទៅហើយ ។ ភពផែនដីទោះស្រេកទឹកខ្សឹង ខះកយ៉ាងណាក្តីបានក្រេបទឹកភ្លៀងបន្តិចបន្តួច គ្រាន់តែនឹងសើមអប់ពងក ប៉ុណ្ណោះ ។ ចាំហើយរដូវហាក់ត្រៀមខ្លួនរួចស្រេចហើយមកវាតទីរង្គត ដីស្រែកសិករធ្វើអោយរហាស់កាន់តែបានចិត្ត មិនខ្វល់ខ្វាយពីការរោយទឹកភ្លៀង ។

នារីព្រាត់ប្តីឈរកណ្តាលស្រែសំលឹងស្រូវសន្ទូងរបស់នាង ទាំងទឹកមុខក្រៀមក្រោះ ។ ដីស្រែមានសំណើមតិចតួច សន្ទូងប្រឹងរែកគុម្ពមើលទៅដូចមនុស្សស្គមស្លេកស្លាំងរៃមទាំងរើបជិតចេញផ្កាផ្លែទៀតផង ។ នាងក្រវីក្បាលតិចៗជាមួយដង្ហើមធំ ។ នាងបារម្ភរកាំងខ្លាំងចំពោះស្រែស្រូវដែលជាអាយុជីវិតរបស់គ្រួសារនាង ព្រោះបើមិនមានភ្លៀងធ្លាក់មួយមេ ឬពីរមេ នាពេលចុងរដូវនេះទេ សន្ទូងដែលកំពុងរើបជិតចេញផ្កាផ្លែនឹងចេញមិនរួច ឬស្កកមិនខាន ។

www.elibraryofcambodia.org

នៅក្នុងភូមិកំពង់ម្លូលស្រែណាក៏ដូចស្រែណាដែរ មានគំនរពងតំរួយ! ទ្រូទ្រញពីសន្ទូង ហើយរលាយបាត់ទៅជាភាពតែមួយជាមួយនឹងសំរបោ ម្ចាស់វា ។ ទំនួញនេះនឹងមិនបញ្ចប់ឡើយ បើគ្មានការរបួងពេកផ្ដល់ភ្លើ សង្ឃឹមពីពិភពនៅខាងលើខ្ពស់រាប់ម៉ឺនតែរសត៍ម្ភៃក្រនោះ ។

ក្រោមបរិយាកាសបែបនេះហើយ ទើបគេឃើញភក្ដីភាពរវាងគូស្នេហ៍ពីរ ស្រែ និងសន្ទូង ។ ទោះបីក្ដៅក្លួកហែងយ៉ាងណាក្ដី ពួកគេនៅតែក្រាញ នសៀវរួមសុខទុក្ខជាមួយគ្នាក្រោមសេចក្ដីស្នេហា។ ពីស្រែប្រឹងទ្រូវគ្នាថា :

...ទាំងទ្រូងខ្លាំងណាស់ម្ចាស់ថ្លៃខ្ញុំអើយ
វស្សារមួយទៀតស្រែប្រាក់ភ្លៀងធ្លាក់
ជាតិជាដីស្រែគ្មានទ្រូពឹងពាក់
នឹងក្ដុំជាក់ក្រោមរស់ស្ទើរស្លូត ។
សន្ទូងស្មោះស្និទ្ធគ្រប់គ្រងដីស្ងួត
នឹងក្ដៅវិត្សតក្លួកហែងសង្ហារ
ពិតពិត្សំណាក់រត់រង់ចាំគ្នា
រស្មីស្នេហាផ្កាពងសន្សើម ។
រាល់ឆ្នាំសន្ទូងបេះដូងថ្លៃថ្លើម
សូមមានជំនឿនៅគង់ជិតគ្នា
បើនឹងត្រូវធ្លាក់ៗពីរស្មា
ដីស្ងួតក្រប់ក្រៅបែកក្លាំងរាងពិត្យា
តើកដៃសំពះព្រះព្រហ្មមានឫទ្ធិ
បង្គុំរង្គៀងពីគស្រែកស្រែកាកុំឈាន
បើគ្មានទឹកភ្លៀងយើងក៏បង់ប្រាណ
ពានភ្លៀងពួនគកន្លងរៀងរហូតវេលា។

នៅពេលក្រោមតែរង់ព្រះអាទិត្យនាវេការស្មៀបក្ដៅហែង ទោះញើស ហូរយ៉ាងណាក្ដី នារីទុក្ខព្រួយហាក់ស្រែងនឹងក្ដៅទៅហើយ ។ នាងក្ដៅចិត្ត ចំពោះរោគដែលមិនភ្លៀងជាងក្ដៅកាយ ។ នឹងហេងរង សភាពក៏តសន្ទូង ផង ទ្រូងនាងប្រាលចេញមកទំនួញខ្សឹកខ្សួលជាមួយទឹកភ្នែកហូរនើន ។ នាងក្ដាប់មាត់តំលឹងទៅមេឃ ហើយស្រែកដេរដៀវថេ : អោយអប្រិយ!

www.elibraryofcambodia.org

Scanned with CamScanner

អោយកំណាច អោយឫទ្ធា អោយរករករោកា អោយររលុក្ដិចម៉ា...អ្នក បង្អុរទឹកភ្លៀងចុះភ្លាមមក អ្នកវិញទទឹង បើពេលនេះខ្ញុំមានវិធីអាចទៅជួប អ្នកបានខ្ញុំនឹងប្រហារអ្នកភ្លាម ខ្ញុំមិនទុកអោយអ្នករៅរានជីវិតធ្វើការ កសិករទៀយ...។ នាងស្រែកតែរកខ្លាំងជាងមុន : "មេឃ មេឃ...បង្អុរ ទឹកភ្លៀងចុះភ្លាមមក សងប្ដីខ្ញុំភ្លាមអក..."។

គ្រានោះស្រាប់តែមេឃប្រែជាងងឹតខ្មៅព្រាំងប្រាត់សុរិយា មានផ្លេក បន្ទោរព្រោតជាមួយផ្គរលាន់គ្រឹលេមខ្ទរអស់ភូមិឋាន ។ បន្តិចមកតំណក់ទឹក ភ្លៀងធំៗស្រក់មកយ៉ាងគំហុកដូចជាមេឃធ្លុះគូទលាន់ស្នូរពប្ញងរ ។ តំណក់ ទឹកភ្លៀងរាប់លានតំណក់ស្រក់ស្រោចពេញរូបកាយនារីកសិករ បីដូចជាមេឃ ខឹងនាងដែលជេរប្រទេចខ្លួន ហើយប្រើអាវុធបាញ់ប្រហារអោយរលាយទៅ ជាផង់ព្រះធរណី ។

នាងស្រែកទាល់តែរំពែកមេឃ ។ នារីសប្បាយចិត្តខ្លាំងណាស់ នាង រត់កាត់ស្រូវឆ្លងពីស្រែមួយទៅស្រែមួយទៀត ទឹកភ្លៀងបានស្រក់ស្រោច លាងផ្ទៃមុខនាងជ្រះអស់ស្នាមក្រៀមក្រោះ ពេកឡើងនូវស្នាមញញឹមប៉ប្រិម ក្នុងក្ដីសង្ឃឹម ។

* * *

តែងវគ្គនេះនៅរាត្រីទី៧ ខែតុលា

ចប់នៅរាត្រីទី៩ ខែតុលា ឆ្នាំ២០០៥

www.elibraryofcambodia.org

Scanned with CamScanner

៥-ក្នុងគ្រាអត់ឃ្លាន

ក្រោយពេលភ្លៀងមួយមេធំនោះ មានទឹកដក់ក្នុងស្រែចិញ្ចឹមគន្លង អោយរស់រហូតដល់ចេញផ្កាផ្លែ ។ ក្នុងលំហើយរដូវស្រែទាំងឡាយរភាក់រលារក្រលេគ្នាតែមួយបាំងបាត់អស់ភ្លឺពកាគតរន្ធឹងក្នុងពណ៌ស្វាររគេរកបង្ហាញនូវប្រណីតភាពគួរគយគន់ ។ វាយោឧត្តររក់រោសដើមស្រូវពេកពោតពិតៗ ដូចស្វាបអង្អែលដោយក្ដីស្នេហ៍ស្និទ្ធ ។

ភោគផលនេះជាមោទនភាពរបស់កសិករ ប៉ុន្តែផ្ទៃដីត្រូវពាក់កណ្ដាលនៅជាដីទទេស្អាតគួរអោយស្ដាយពន់ពេក ។ កសិករភាគខ្លះកំពុងរងការខ្វះខាតស្បៀងអាហារ ព្រោះឆ្នាំទៅជួបគ្រោះរាំងស្ងួតធ្វើស្រែមិនអស់ដីដែរ ហើយទុក្ខលំបាកនេះនឹងបន្តទៅទៀត ។

នាវេលារសៀលមួយនោះនារីព្រាត់ប្ដីកាន់ចបជីក និងកញ្ជើមួយដើរទៅទីទួលដាំដំឡូងមីនៅក្រោយផ្ទះ ។ នាងជីកកាយដីរកមើមដំឡូង ។ ជីកបានហើយនាងយកដាក់ក្នុងកញ្ជើ ។

នាងប្រឹងជីកកាយដីទាល់តែចេញញើសហូរតាមដើងសក់ ។ ខណៈ

www.elibraryofcambodia.org

Scanned with CamScanner

នោះមានបុរសវ័យសាមសិបឆ្នាំម្នាក់ដើរមកជិតនាង ដោយក្នុងដៃកាន់ថង់ក្រហមមួយផង ។ ឃើញផ្កាពីបុរសម្នាក់នេះ នាងលើកដៃសំពះជំរាបសួរ ហើយបុរសសំពះតបវិញជាការគួរសមរវាងគ្នានិងគ្នាក្នុងនាមជាអ្នកជិតខាង។

បុរសពោលទៅកាន់នាងទាំងហុចថង់ក្រហមអោយផង ៖ "លំអង ខ្ញុំដឹងថាគ្រួសារលំអងកំពុងជាប់រវល់ ដោយក្តីអាណិតអាសូរក្នុងនាមជាអ្នកជិតខាង ខ្ញុំសូមជួយរំលែកទុក្ខលំបាកដោយផ្តល់អង្ករបន្តិចបន្តួចនេះ សូមនាងទទួលយកទុកហូបចុះ" ។ លំអងស៊ំឡើងមុខបុរសពោលទាំងញញឹម ៖ "ខ្ញុំសូមអរគុណចំពោះសន្តានចិត្តល្អរបស់បងប្រុស ប៉ុន្តែទាំងខ្ញុំ ទាំងបងប្រុសសុទ្ធតែជាអ្នករងគ្រោះដោយសារសង្គ្រាមដូចគ្នា ខ្ញុំដឹងថាគ្រួសាររបស់បងប្រុសមិនជាសល់ស្បៀងអង្ករប៉ុន្មានទេ សូមបងប្រុសទុកអង្ករនេះហូបវិញចុះ" ។

បុរសពោល ៖ "ប្រពន្ធខ្ញុំស្លាប់ទៅជាងកន្លះឆ្នាំមកនេះបាក់បំភ្លេចទុក្ខ ហាក់រំដោះខ្លួនចេញពីទុក្ខលំបាកនេះ គ្រួសារខ្ញុំមានតែម្តាយ និងកូន មិនអ្វីទេ ខ្ញុំអាចរំលែកបាន ។ ក្នុងនាមជាអ្នកភូមិផងរបងជាមួយគ្នាពេលឃើញជួបការលំបាកធ្វើម្តេចនឹងមិនជួយសំរាលខ្លះ នៅពេលមានលទ្ធភាពនោះ កុំគិតពីអ្វីផ្សេងពាក់ទុកការនេះគ្រាន់តែជាសេចក្តីចិត្តមួយទៅចុះ...សូមលំអងទទួលអង្ករនេះទៅ!" ។

លំអងលូកដៃទទួលថង់អង្ករពីបុរសអ្នកជិតខាង។ ស្នាមញញឹមប៉ប្រិមរបស់នាងប៉ុននេះបានរសាយបាត់អស់ ហោរទឹកភ្នែកពេញពោរពេញនៅលើភក្ត្រា ទឹកធ្លាក់ស្រក់ហៀរពេញនៅលើកែវភ្នែក ។ នាងយំព្រោះរំភើបចំពោះទឹក

www.elibraryofcambodia.org

Scanned with CamScanner

ពិត្តសប្បុរសការរះដួលគ្នាក្នុងគ្រាលំបាកក្រាន ។ ពុក្កជាពិការធ្វើបាន(គ្រួសារនាង ធ្លាក់ទៅក្នុងគ្រោះលំបាកក្រាន តែបុរសម្នាក់នេះជួយនាងពីភាពក្រខ្សត់របស់គេ។

កន្លះខែមកហើយគ្រួសារលំបាំងទទួលទានដំឡូងមីជំនួសបាយ ព្រោះស្ទើរតែភ្លាំក្រាហ ។ ស្ត្រីមួយប្ដីក្រីក្រកតិកព្ធចេញលក់ ប៉ុន្តែពិណពងទឹកចិត្តអ្នកផ្ដល់ជំនួយ ដូច្នេះនាងត្រូវតែទទួល ។ ទឹកចិត្តរបស់អ្នកក្រីក្របរបួច បាននឹងផ្ដូងខែ ទោះជាជីពពកខ្មៅខ័បិទបាំងព្រះអាទិត្យ បើមានប្រទ្បាះ ប្រាក់ពងតូចមួយនឹងចាំងជះរស្មីមកភពផែនដីមិនខាន ។ អ្នកភូមិព្រៃដួល មានព្រំពណ៌ជួយអាករភាសាគ្នាមិនខុសពីជនជាតិខ្មែរទូទៅឡើយ។ ដូច្នេះទៅ វិញក៏មានមនុស្សអត្តទត្ថប្បុគ្គលមួយចំនួនដែរ ។

នារីខូះខាតដាក់ថ្នក់ក្រមាភ្លេចទៅក្នុងកញ្ជើដំឡូង ។ នាងញញឹមទាំង ទឹកភ្នែករនៅហូររហៀរនៅឡើយលើកដៃសំពះបុរសចិត្តល្អ : "បងសុគុណ ខ្ញុំសូមអរគុណកំពោះទឹកចិត្តដ៏សប្បុរសរបស់បងមកលើក្រុមគ្រួសារខ្ញុំ ។ ខ្ញុំ ក៏សូមថ្លែងអំណរគុណចំពោះម្ដាយរបស់បងប្រុសដែរ សូមបងប្រុសជួយ ជំនាំទៅប្រាប់គាត់ផង ។ គ្រួសារបងប្រុសក៏មានការខ្វះខាតដូចគ្នាដែរ ប៉ុន្តែ សុខចិត្តបេះបោកហែកកំរៃកអោយដល់គ្រួសារខ្ញុំ ។ នេះជាទឹកចិត្តសប្បុរស គំរូដែលខ្ញុំត្រូវតែគោរព ហើយចងចាំក្នុងចិត្តជានិច្ច ។

សុគុណពោលទៅកាន់នាង : "កុំចង់អីណា អង្ករមួយថ្នក់ក្រមាមិន ជាគុណត្រីយអ្វីទេ! ក្នុងនាមជាអ្នកជិតខាងបើនាងខ្វះខាតខ្ញុំជួយ ហើយបើខ្ញុំ ខ្វះខាតនាងជួយវិញ ជារឿងធម្មតា ប៉ុន្តែអ្វីដែលសំខាន់សូមអោយសុរិន

www.elibraryofcambodia.org

Scanned with CamScanner

អាក្រក់របស់ពួកយើងជាកសិករនៅរំពាក់ទៅឆ្នាំ...។

លំចង់ពោលបន្ត : "ហ៊ឺ សូមឆ្នាំក្រោយមេឃភ្លៀងគ្រប់គ្រាន់ ហើយកុំខ្វះទឹកធ្វើស្រែដូចឆ្នាំនេះទៀត ។

ពួកគេឡើងលំចង់យកអង្ករបានពីទឹកចិត្តសប្បុរសរបស់អ្នកជិតខាងដាក់ដាំបាយ ។ ពេលដាំឆ្អិនហើយនាងដួសដាក់អោយកូនទាំងពីរទទួលទានធ្វើអោយពួកគេរីករាយយ៉ាងខ្លាំង ។ ពួកគេហូបតែជីឡុងប៉ុន្មានពេលមកហើយ ពេលបានបាយទោះជាម្ហូបត្រីងៀត ត្រីឆ្អើរវាក្លាយជាអាហារពិសេសរបស់ពួកគេទៅហើយ ។ ក្មេងទាំងពីរមិនខ្វល់នឹងសួរម្តាយគេបានអង្ករមកពីណាដាំបាយឡើយ ។

រៀបចំអាហារអោយកូនរួចរាល់ហើយ លំចង់ដួសបាយដាក់ចានមួយទៀតកំពង់របហូតររត់ពីឆ្នាំងយកទៅអោយឪពុកក្មេកនាង រីឯលោកគាត់ធ្វើរោងតូចមួយនៅក្រោមដើមត្នោតខាងក្រោយផ្ទះសំរាកម្នាក់ឯង ។

ឃើញកូនប្រសារៀបបាយភ្ជាប់ជាមួយត្រីងៀតអោយគាត់ ពុទ្ធាចារ្យស៊ុំសំលឹងមុខនាងពោលមួយៗ : "កូនស្រីអើយ! នេះឬជាអាហារពិសេសរបស់គ្រួសារយើង! វាមិនពិសេសសំរាប់ពុកឡើយ ព្រោះពុកចាស់ហើយ ទោះប្រឹងលេបអាហារឆ្ងាញ់ឬមិនឆ្ងាញ់ យូរឬឆាប់ព្រលឹងពុកនឹងឃ្លាតឆ្ងាយពីរូបកាយជ្រីវជ្រួញនេះទៅរកត្រើយនៅភពថ្មីមួយទៀត ។ ផ្ទុយទៅវិញវាពិសេសសំរាប់រូបកូនដើម្បីរស់នៅចិញ្ចឹមបីបាច់កូនៗ វាសំខាន់សំរាប់ចៅៗទាំងពីរ ព្រោះពួកគេត្រូវការភាពធំធាត់ និងកសាងវាសនាអនា

www.elibraryofcambodia.org

Scanned with CamScanner

គករបស់ពួកគេ។ កូនស្រី យកម្ហូបបាយនេះទៅវិញចែកគ្នាហូបជាមួយ កូនៗទៅកុំបារម្ភពីពុកអី ផ្តល់តែនំឡាំងមីមួយដើមដូចរាល់ដងទៅពុក អាចបានហើយ" ។

ពីវាចានេះបំផុសខ្លោចផ្សាក្នុងចិត្តលើកដៃសំពះឪពុកក្មេក ពោលយ៉ាង សុភាព : "លោកឪពុកជាទីគោរពនៃកូន! នំឡាំងមួយដើម កូនលាក់ទុក ទុកសំរាប់បរិភោគដោយខ្លួនឯង ព្រោះបាយមានតិចតួចបានពីអ្នកជិតខាង នេះ មិនសក្តិសមសំរាប់កូនដែលមានកំលាំងកំហែងពេញពោរឡើយ។ ពាក្យចាស់លោកពោលថា "ធ្វើបុណ្យចាស់ខែភ្លឺ" ដូច្នេះលោកឪពុកចាស់ហើយ សូមពិសាបាយនេះចុះកុំខ្វល់ពីកូន" ។

ព្រឹទ្ធាចារ្យស្ទើរខ្លោចចិត្តចំពោះទឹកចិត្តយកចិត្តទុកដាក់របស់កូនប្រសាថ្លៃ ពោះទូបគាត់ : "កូនស្រីអើយ! ទឹកក្នុងទន្លេបើហូរទៅខាងកើតគឺហូរទៅខាង កើតទាំងអស់គ្នា បើហូរទៅខាងលិចគឺហូរទៅលិចទាំងអស់គ្នាមិនមានទឹក ក្នុងទន្លេណាមួយហូរបញ្ច្រាសទិសគ្នាឡើយ ។ យើងរួមរស់នៅ រួមគ្រួសារ បើ លំបាកគឺលំបាកទាំងអស់គ្នា បើស្រណុកស្រណុកទាំងអស់គ្នា បើហូបឆ្ងាញ់ គឺហូបឆ្ងាញ់ទាំងអស់គ្នា! ពុកហូបឆ្ងាញ់ម្នាក់ឯងម្តេចនឹងកើត ខណៈកូន អត់ឃ្លាន! ក្មួយកូនចែករំលែកបាយនេះពាក់កណ្តាលយកទៅហូបវិញទៅ!" ។

ដោយមិនចង់អោយគាត់ទើសទាល់ក្នុងចិត្ត នាងបង្ខំចិត្តនិយាយភូត ភរគាត់ទាំងធ្វើទឹកមុខញញឹម : "អរគុណលោកពុក! ការណ៍ពិតក្នុងឆ្នាំង នៅសល់បាយខ្លះដែរ កូនអាចហូបបាន សូមលោកពុកពិសាបាយនេះទៅ

www.elibraryofcambodia.org

Scanned with CamScanner

នេះជាសៀវភៅដែលកំពុងចេញលក់

សូមអញ្ជើញរកជាវនៅតាមបណ្ណាគារ
និងបញ្ជរលក់សៀវភៅគ្រប់ខេត្ត-ក្រុង

www.elibraryofcambodia.org

ISBN-9789995076504
9 789995 076504

Scanned with CamScanner

ការផ្សាយសៀវភៅនេះជា eBook បានបង្កើតឡើងដោយ
មូលនិធិខ្មែរសម្រាប់ការសិក្សា និង ករុណាខ្មែរ
ដើម្បីបម្រើប្រយោជន៍ជាសាធារណៈ ដោយមិនគិតកម្រៃ

យើងខ្ញុំជាកូន ខ្ចៅ យ៉ាត់ណៃ, ខ្ចៅ សុផល, ខ្ចៅ វិសាល, ខ្ចៅ រ៉ាមុន, ខ្ចៅ ភារាដា, ខ្ចៅ ចំរើន និង ខ្ចៅ ភារី
បានឧបត្ថមការផ្សាយសៀវភៅនេះជា eBook

ដើម្បីឧទ្ទិសកុសលដល់វិញ្ញាណក្ខន្ធ ឧបាសក ខ្ចៅ ៣ញ និង ឧបាសិកា ឈរ យឿន

(ឃុំកំពង់ឃ្លាំង ស្រុកជីក្រែង ខេត្តសៀមរាប)

ស្កេនជា eBook ដោយ ហៃ គីមស៊ាន
ខែមិនា ឆ្នាំ២០១៧
បើលោក លោកស្រី ចង់បានសៀវភៅនេះ ឬអានបន្តទៀត
សូមទិញ ឬជាវពីអ្នកនិពន្ធ
ឬបណ្ណាគាដោយផ្ទាល់ដើម្បីគោរព "ក្សារសិទ្ធ" របស់អ្នកនិពន្ធ។
យើងខ្ញុំ ពុំមានការប្រស្រ័យទាក់ទង ដោយប្រភេទណាមួយជាមួយ
អ្នកនិពន្ធ ឬបណ្ណាគាទេ។

សូមអរគុណ
ខ្ចៅ យុនសំរ៉ង
ប្រធានមូលនិធិខ្មែរសម្រាប់ការសិក្សា និង ករុណាខ្មែរ

www.elibraryofcambodia.org

Scanned with CamScanner